# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ បោះពុម្ពផ្សាយ អំពីពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រៈ ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម, បណ្ឌិត នៅ ពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកដំណឹងសាសនាៈ ព្រះគ្រូសុវណ្ណញាណ សួរ-ហាយ ក្រុមជំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ

## បញ្ជីរឿង

*ផ្នែកអក្សរសាស្ត្រ* — ទំព័រ

| | | |
|---|---|---|
| លោក ហេង-ប៉ាន់ | កង្កួលស្នេហា (តមក) . . . . . . . . . . | ១១៣ |
| ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម | ឯកបហស្រីត្រី ភាគទី១០ (តមក) . . . . . | ១២៨ |
| ឃុន សុន្ទរមេធី ញូង-សៀង | មិត្រសំឡាញ់ខ្ញីបាក់ភ្លា . . . . . . . . . . | ១៥២ |

*ផ្នែកសាសនា*

| | | |
|---|---|---|
| ឃុនសុវត្ថិវេទី យូរ-អ៊ុន | មង្គលទិដ្ឋកថា (តមក) . . . . . . . . . . | ១៥៥ |
| ព្រះមហាបទុម មាឃ-ស៊ុន | ផ្លូវវត្តបរិយាយ (តមក) . . . . . . . . . . | ១៦៥ |

ឆ្នាំទី ១៨ — លេខ ៣ ខែម៉ារ្ស ១៩៤៦ — ដំឡៃផ្សាយ: ១ ឆ្នាំ ៣៥ រៀល ។

1946

# កំពូលស្នេហា

## លោកហេង - យ៉ាត់ រៀបរៀង

(តមក)

លោកគ្រូមិនបានចាប់ស្ដាប់ ពួតែរឿង ដូចស័ព្ទយំគ្រហឹម ឃើញអាចារ្យកំពុងហុតផែ ក៏យល់សេចក្ដីស្ដើយថា "បាទ! កុំព្រួយលោកអញ្ជើញពិសាចុះ" ។

អាចារ្យទឹកកង់សើចឈ្លក់ទឹកតែ គ្រហមមុខដល់ត្រចៀកភ្លែក ណាដនេគ្រនារីអត់មិនបានក៏ងាកមក មើលមុខលោកគ្រូហើយនាងក៏ញញឹម លោកគ្រូដោះសេចក្ដីស្រស់ទៅថា "អ្នក! មិនពិសាតែទេឬអ្វី? តែជាគេសង្ឃឹមថាឯកឡាំងស្រស់ស្រួលដែរ" ។

"ចាះ កុំព្រួយនឹងខ្ញុំអីចាះ ខុសជាយ៉ាងណាក៏ខ្ញុំមិនប្រឡូកខ្ទង់ពីយ៉ា-ណាក់ដែរ មិនហើយឲ្យត្រូវហួសប្រមាណ" ហើយនាងក៏សើចព្រមនឹងអាចារ្យទះសំនាង ។

លោកគ្រូមិនដឹងជានាងនិយាយចំអកឲ្យ ក៏សើចជាមួយនឹងគេដែរ រួចលើកតែងតែទឿងពីក្បែ ចុះទៅ ដល់ឃើញណាដនេគ្រនារីមើលខ្លួនដោយយកចិត្តទុកដាក់ ក៏ភ្ញាក់ខ្លួនភ្លេចគិតថាចិតខ្លួន លើកតែងទៀតហុត ដល់លោកអណ្ដាតក៏ភ្ញាក់ខ្លួនព្រោតនឹងខ្ញាក់ចេញមកខាងសងខ គ្មោះហើយទំលេបចាំងក្ដៅទៅ ធ្មេញក្រញូវត្រូវបាញ់ចំព្ញើចចូលគ្នា យក

ដៃកៃដើមព្រូន នាំឲ្យអ្នកតាំងពីនោះសើចកាន់តែខ្លាំងឡើង សោកក្រៀ ម៉ក្រៀមនឹងខ្លួន ស្ទើរនឹងរំដែកព្រះនេត្រឲ្យហាក់ខ្លួនទៅ តែមិនដឹងធ្វើ ដូចម្ដេច ទើបតាំងធ្វើជាសួរអាចារ្យថា “ អាចារ្យបានរៀនគ្រូសប្បាយសើច ហើយឬ? ប្រាប់ខ្ញុំឲ្យបានដឹងគ្រាន់នឹងសើចផង” ។

“ ចាះ ” លោកជនេត្រនារីឆ្លើយជូនឡើង “យើងសើចពិតស្ទើរនឹងបែក មួយនោះ ហើយឃើញចំណាំល្អទាំងដេញចឹក លុះដិតផល់ហើយក៏ស្ទុះទៅ គ្រប់កកក្រាប្រណាំ ទុះបង់ចំណាំភ្ញាក់ឯចំណាប់ក្រឡាប់ក្បាលផល់ដី តែម្ដង គួរឲ្យចង់សើចមែនទេហ៎! គោតក៏គោតម្ល៉េះ! អាណិតគ្នាពេក ស្ទើរនឹងស្លុតស្មើមទៅហើយ” ។

“ដំកចប្រសាសន៍អ្នក ការគ្រងនេះមិនគួរឲ្យចង់សើចទេ ខ្ញុំបាទ មើលឃើញថា ល្បុកដែលអ្នកអាចប្រសាសន៍អម្បាញ់មិញនេះ ជា ល្បុកលោនជម្គាដែលតែងលេងគ្រប់ទិសគ្រប់តំបន់ក្នុងលោកនេះ មិន បំពោះលើរូបណាសាសន៍ណា ភាសាណាឡើយ នឹកឡើងគួរឲ្យសង្វេគ ណាស់ពេក សត្វដីនិងកកាលមើបានប្រទះចំណាំហើយ តែងចំរៃតាម មើលដល់ក្រោយខ្លួន ព្រេងគិតទឹកនាផល់អ្វីទាំងពួង ចិត្តប្រាថ្នាតែលើ ចំណាំនោះប៉ុណ្ណោះ ទុកជាជេកដើរឈរអន្តរាយក្ដី ក៏ឃើញតែរូបចំណាំ នោះជាប់នឹងភ្នែក គាំងចិត្តប្រាថ្នាតែឲ្យបានមកជិតខ្លួន តែចំណាំនោះ តែងតាំងគេចមុខធ្វើព្រងើយ បែរជាចំអកឡកឡឺយធ្វើឲ្យគ្នាតេតទុក

គួរតែអាណិតដល់គ្នាដែលកំសត់អត់ឃ្លាន តែអ្នកយល់ឃើញដូចម្តេច ? ខ្ញុំសង្កេតឃើញថា អ្នកមានអធ្យាស្រ័យទន់ភ្លន់ មានចិត្តអាសូរ ករុណាដល់ទុក្ខនៃកៀនមនុស្សផងគ្នា បើជាគិតដូច្នោះមែន សុំអ្នកចាត់ គំនិតយោបល់យល់ដូចខ្ញុំដែរមែនទេអ្នក ? ។

ណាផែនស្រីនារីត្រូវសួរចំពោះខ្លួនដូច្នោះ ក៏ឡើងមុខក្រហមព្រឿងៗ ភាគមុខបញ្ចេញកមិនឡើយ មិនបានតបឡើយថាមនុស្សបែបសោភ័ត្រ យល់សេចក្តីជ្រាលជ្រៅយ៉ាងនេះ ទោះបើងសំដីលែបខាយដល់មុំ នឹក ចង់ខឹងទឹងគេហ៊ាននិយាយបែបនោះផង ព្រោះទើបនឹងប្រសប់ប្រយោជន៍មួយ ម្តេចក៏ប្រាជ្ញប្រាយខ្ទីជន់ឡូនាងយ៉ាងហ្នឹង ផញ្ជឹងគិតមួយស្របក់ទៅ ឃើញត្រូវតាមពាក្យគេនិយាយមែន ទើបនាងខ្ជិបមាត់ដោយសេចក្តី អៀន ព្រោះបានថាសើចផ្ទាល់ទៅហើយ ដូចជាមិនអាណិតដល់គ្នា សោះ ដែលខំប្រឹងរកលេងមិនមានលោះថ្ងៃណា សេចក្តីប្រាជ្ញារបស់ សោភ័ត្រក៏ស្រពេចស្រពិលដល់ចិត្តនាង ទាំងនាំឲ្យស្ងួតស្ងប់មួយរំពេច ពុំដឹងដោយហេតុអ្វី គំនិតថ្មីយ៉ាងជំនែខ្សែកក្នុងខួរក្បាលរបស់នាង ទើប បណ្តាលឲ្យនាងញញឹមរកពីយ៉ាណាត់ដោយមិនច្បាស់ជាមានទំនងចិត្តបែប ណា ម្រាមដៃអន្ទោលទង់កន្សែងយ៉ាងរវើរវាយ ដល់សោភ័ត្រសួរសាំឡើង ទៀតថា "អត់ទោសអ្នក អ្នកមិនឆ្លើយបញ្ហារបស់ខ្ញុំផងទេ? បានជា

ខ្ញុំកាត់ចិត្តហ៊ានសួរ ព្រោះសង្ឃឹមថាអ្នកនឹងតបមកវិញ តើអ្នកនឹងទុកឲ្យខ្ញុំមានសេចក្ដីស្ដាយក្រោយត្រឡប់ទៅផ្ទះវិញឬ?

នាងក៏ភ្ញាក់ព្រើតឆ្លើយយ៉ាងរហ័សថា "ចា៎ះខ្ញុំ . . ." ដល់ក្រែងនេះក៏ងាកទៅមើលមុខអាចារ្យ ជាការអង្វរឲ្យជួយតែនាងផង ។

អាចារ្យក៏បញ្ចប់សេចក្ដីឲ្យថា "លោកគ្រូឯងនៅឈ្លបសួរដល់ណាទៅទៀត ឆ្មាតាជីងចក់មិនដែលទៅស្ងៀមឲ្យចំណីរត់ចូលមាត់ឯងៗទេ បើគេស្ងើចនោះគឺគេពេញចិត្តណាជីងចក់គណាន មែនទេ?" ។

ល្ងាចនៃព្រឹកនៀនលាអាចារ្យតទៅផ្ទះ ដំណើរនាងល្មាសល្មមទន់ភ្លន់ទាំងដៃជើងគួរជាទីទស្សនា នាងចុះទៅហើយលោកគ្រូនៅតែតាមមើលនាងទៀត ប៉ុន្តែត្រចៀកស្ដាប់សូរស្បែកជើងក្រសួបន្តិចសូរទៅឆ្ងាយ ។

ស្ដាយអើយសែនស្ដាយ! មិនគួរនិយាយឲ្យនាងតែសោះ! ។

## វគ្គទី ៤

## ហៅសែនរំខាន

ព្រះចន្ទពេញបូណ៌មី បញ្ចេញរស្មីត្រាណត្រចះលើធម្មជាតិស្រស់បំព្រង ពពកសក្បុសច្បាស្អាតវិស័យដូចសំឡី ណណាតឲ្យទៅឡើង ឯអាកាសរំហាស់ផ្លូវដុំជាធុំធំ ត្រឡូលដូចពកមេឃ ដូចសាក់សរឡឹម

ទៅឯជើងមេឃប្រផេះគ្នាជាល់រាប់លំដោយ  នាំឲ្យនឹកស្មានថាជាម បុណ្យប្រាសាទឡើងតែងទេវាល័យ  មុខគួរឲ្យស្រណោះស្រណោះអាឡោះ អាល័យអណ្តែតអណ្តូងលិចលង់ណាស់ ។

យប់នោះសោភ័ក្ត្រពេញចិត្ត  នៅតែឯងឯការពុំប្រាថ្នាចូលសម្រាន្ត ទីនិទ្ទជិតទ្វារ  ដើរក្រឡាយមៀងមើលតារាករាំងដែលរះលើផ្ទៃអាកាសទាក់ល ក្ខណ៍ ពុំសេចក្តីសុខកាយសប្បាយចិត្ត! ។ ថ្ងៃនេះ សោភ័ក្ត្រខុសធម្មតា ទេតើ! មានហេតុភេទអ្វីបណ្តាលឡើងក្នុងចិត្តឬ? បានជាថ្ងៃនេះហើយមិន ភាន់ចូលការដំណេក យប់ជ្រៅណាស់ទៅហើយគេដេកស្ងាត់ សល់តែ សត្វប្រចៀវហើរក្បៀលផ្ទាត់ក្រក្រហារ ។

លុះនាឡិកាក្បាលម៉ោង ១ ទើបសោភ័ក្ត្រភ្ញាក់ខ្លួនចូលទៅបន្ទប់  មុន នឹងដេកនៅលើគ្រែនោះ  សោភ័ក្ត្របានសំឡឹងមើលមុងដែលផាត់ផាយតាម ខ្យល់ រួចក៏ញាញឹមយ៉ាងស្រស់ ព្រោះគ្រប់ផ្ទៃសេចក្តីសុខវណ្ណាក់ពេញ ខ្លួន ហើយនាំឲ្យនឹងតែពីសប្បាយ ពងកាយដូចជាអណ្តែតគ្មានជិតផុតពាល់ លើអ្វី បែរទៅទិសណាក៏ដូចជាទន់ល្ហើយ បុផ្ផាផុតក្លិនក៏បិទស្និទ្ធនៅឯង ។

សេចក្តីសុខបានគ្រប់គ្រងសោភ័ក្ត្រ  ឲ្យដេកលក់ស្រួលរហូតដល់ ពេលភ្ញាក់រួចក៏ឆ្ងោលទៅគ្រប់ធុបធ ។ ចុះសេចក្តីសុខប្រែកេទនេះកើត ឡើងដោយហេតុអ្វី? សោភ័ក្ត្រក៏មិនបានសាកសួរដល់ខ្លួនឯងដែរ ករហេតុ នឹងបង្ហួយជាប្រយោជន៍អ្វីដល់គេ  បើគេត្រូវការតែសេចក្តីសុខ  គ្រាន់

រងៀតតែសេចក្ដីទុក្ខបានខ្លះ   តែសោកក្រមិនបានក្ដួចលោតអ្នកដ៏មាន គុណមាំងពីរព្រមទាំងបងប្រុសនោះទេ   គឺគ្រាន់តែបានស្បើយទុក្ខធ្ងរម្ដ ងាចក្រែងមិនបានឃើញមុខគេទៀតប៉ុណ្ណោះ ។

ឯសេចក្ដីសុរនោះ   កំណត់ឲ្យឃើញជាក់ស្ដែងថា   សោកក្របាន អាយុ ១៨ ឆ្នាំហើយ ជាគ្រឿងសំគាល់ឲ្យដឹងថា   កុមារបានផ្លាស់កែវ ពោនដើរចូលកាន់ក្រសែជីវិតផតកុំត   ពោនចូលហើយទៀត គគ្រឹម គគ្រេងដោយមានក្ដីក្ដាត់ប្រឹតដេញដំរួល ។

ព្រះអាទិត្យទើបនឹងចេញមាតការទិត្រា រះក្ដីបព្រាស់ស្រឡះពេញផែ ដោយការស្មើស្រទន់លើផ្ទៃកបស្មើនៃមហាសមុទ្រ   ដែលប្រាសចាករលក នៅពេះត្បូ-ជំនឺងជុំសិលា   ជាទីស្នេហានៃមិត្តភក្ដិទាំងពួកកំឡោះ ។ អាកាសក៏ព្រោតព្រានសប្បាយគួរឲ្យស្រឡះដល់ចិត្ត   មានខ្យល់រំភើយ ល្ហើយៗ អប់ម្យោកឥកាយ ហើយទន់ភ្លន់   ចំណែកផ្ទៃមេឃក៏ចំឡែកអស្ចារ្យ គួរពិតពិលមើលមើលមិនជាក់ភ្នែក   ចំពួតឯណាមួយដែលរបងបោញ រំពនឹកស្មើបផល់ខស្បូនកាតាយកំឯកបែបនេះ ?   មិនចង់គ្រាប់ឆាត់ បោកាផលពីជាទីមនោមេ្យ   មិនចង់ប្រះដូនបេតសេនលើផ្ទៃកដ៏ខនឹ ពេរីយ មិនចង់ហុចដៃតាំងពីរដោយសោះស្រីគ្រកព្រះស្ទ្រក្រិបះគ្រចង់ ដែលញញឹមបើតព្រះទេក្រក្ដីថា   សំឡឹងមើលមកដោយសេចក្ដីមេត្តាដ៏ លើសរ ។

នរណាហ្នឹងដែលមានចិត្តស្លូត ដាក់ស្ពានឲ្យនាងសោភ័ក្ត្រឆ្ពោះទៅឋានទាល់? នាក់អស្ចារ្យដែលត្រូវនាំសោភ័ក្ត្រឆាក់ផ្ទែងទៅកេស្ពានមនោរម្យរមសុខ? រូបអ្នកនោះឯងមិនទាន់បញ្ជាក់ដល់ចិត្តនៅឡើយ គ្រាន់តែប្រហាក់ប្រហែលប៉ុណ្ណោះ ហើយរូបនោះនឹងប្រាកដនៅថ្ងៃដែលសេចក្តីត្រូវការកើតមានឡើងលើរូបនោះ ។

ល្ងាចមួយ សោភ័ក្ត្រដើរមកលេងផ្ទះអាចារ្យតាមធម្មតា ស្រាប់តែប្រទះនឹងណុជនៃត្រនារីកណ្តាលផ្លូវ នាងកំពុងឡើងជិះឡានជាមួយនឹងឪពុកម្តាយបងប្អូនរបស់នាង មានទាំងហិបកាលិសផងទំនងដូចជាធ្វើដំណើរទៅឆ្ងាយ ។ សោភ័ក្ត្រក៏ហួសដល់សំណាក់អាចារ្យទើបបានសេចក្តីថា នាងមិនសប្បាយក្នុងខ្លួនទៅលេងខ្សល់កាកាសឯកោបាន ១ អាទិត្យ ។

សោភ័ក្ត្រអង្គុយលេងនៅទីនោះបានបន្តិច ក៏ប្រញាប់លាអាចារ្យវិលទៅលំនៅវិញ ព្រោះដូចជាបន្ទោលកង្វល់ក្នុងចិត្តពេក "ដូចម្តេចក៏ឆាប់ទៅម៉្លេះសោភ័ក្ត្រ? ។

"បាទ! ខ្ញុំបាទមិនស្រួលក្នុងខ្លួន ដូចជាតឹងមុខតឹងមាត់អស់យ៉ាងហើយក្នុងថ្ងៃនេះ" ។

"ផឹកថ្នាំសិន ចេដូច្នោះ" ។

" ចា៎, អាគុណ! កុំព្រួយលោកអាចារ្យ ខ្ញុំទៅសម្រាកខ្លួនមួយសន្ទុះស្ងាត់ហើយ " ។

រួចសោភ័ក្ត្រក៏វិលត្រឡប់មកលំនៅអាត្មាវិញ កន្ទក់កន្ទេញនឹកថា " ឱនាងមិននៅផ្ទះទេតើ អាត្មាអញបានឃើញមុខនាងអស់កំណត់មួយការវិញ ហើយក៏នឹកអផ្សុកក្នុងចិត្តពន់ពេកយ៉ាងមួយរំពេច ត្រឡប់មើលចិញ្ចាប់ៗឃើញដូចជាស្ងាត់ដែលមិនជាទីសប្បាយ នូវឲ្យទៀយណាយ ក្រោយដែលដើរទៅលេងផ្ទះអ្នកជិតខាង ក៏ខ្លាំងតែគេនិយាយពាក្យដដែលគ្មានខ្លឹមសារ ជាសំដីពោរពេញឥតប្រយោជន៍ ។ សោភ័ក្ត្រគេចមកវិញទាំងគិតដល់រូបខ្លួន " ចុះអាត្មាអញថ្ងៃនេះ ដូចម្ដេចក៏ប្លែកខុសធម្មតាអម្ល៉េះ មិនបេះពីកាយដល់ក្លោះ គ្រាន់តែក្ដួចណាជនេត្រទៅបាត់ប៉ុណ្ណឹងក៏!..... ។

ឈ្មោះនេះចេញមកមិនទាន់ផុតពីមាត់ សោភ័ក្ត្រក៏កើតក្នុងចិត្តញើរចំប្រប៉ក្សាម នៅស្ងៀមមួយស្របក់ធំ ស្រាប់តែរូបនាងលេចចិញ្ចែងទៀងក្នុងចិត្តរបស់សោភ័ក្ត្រ កាន់តែច្បាស់ចត្តឹងឆ្ងើតៗ ត្រៃដូចធម្មតាស្តែងជាប់ក្នុងចិត្តនោះតែលើរល្បងច្រាក់ ៈ ណាក៏ដោយព្រៃនារី ឈ្មោះនេះពុំពេញដួងហឫទ័យរបស់សោភ័ក្ត្រយ៉ាងដិតដល់ ៈ ថ្ងៃនោះដែលសោភ័ក្ត្រនែងសន្ទុះឈ្មោះនេះល់ពេក ចួនក៏ភ្ញាក់ស្រែកខ្លាំងៗ ប៉ុន្តែមិនដឹងខ្លួនបានតាំងឮយ៉ាមកានោះឈ្មោះនោះ ព្រោះហាក់ដូចជាមន្តគាថាដ៏ស័ក្តិ

សិទ្ធិមួយចង់ ដែលគាប់ទាំងស្រុងសពក្តីប្រមាទ ៗ សោភ័ក្ត្រតែងថា "ខ្ញុំមាតាគញ្ញស្រឡាញ់ខាងវេជ្ជា ក៏បញ្ចប់ប្រាប់ថាមែន ទើបសំដែង ទឹកចិត្តរបស់ខ្លួនថ្លែងចេះ ខ្ញុំណកុំនេះត្រូវការជីវិតអភិជន មេ្តចក៏ចេកឃ្លាត ទៅបាត់ ឲ្យបងនៅស្ងាត់តែម្នាក់ឯង នេះព្រោះតែជាប្អូនមិនអាស្រ័យផល ដើម្បីទ្រទ្រង់បងនូវអ្វីទេ ... សោភ័ក្ត្រ ! សោភ័ក្ត្រ មេ្តចក៏បាត់ស្មារតី ក្លាយ ពាក្យថាបងនឹងប្អូនគេនឹងឆ្ងាយពីឡោមឈ្មួញណាស់ វិស័យមេឃ ទឹកដី មិនគួរយកមកប្រើសោះ ហើយខ្លួនឯងជាបណ្ឌិតស្តាប់ មេ្តចក៏ប្រាថ្នា ផល់ទៅព្រះបន្ទូលលើមេឃ "

ទុកជាពិភាក្សាណាផល់ហានៈស្ពឹកស្រពន់របស់ខ្លួនយ៉ាងណា សោភ័ក្ត្រក៏ នៅតែនឹកគិតផល់នាងជានិច្ច មិនចេះហោរស្រែកស្រាន្តឡើយ ទោះ ធ្វើការក្តី ដើរក្តី ដេកក្តី សោភ័ក្ត្រឃើញតែរូបនាងជាប់ជានិច្ច រំខាន ចិត្តអន្ទះសាររង់ចាំពេលនាងត្រឡប់វិលមកវិញតែម្ដងទៀតថា "ខ្ញុំនៅបួន ថ្ងៃទៀត! នៅបីថ្ងៃទៀត! នៅពីរថ្ងៃទៀត! នឹងបានក្បួនប្អូនកំរងឧ ប្អូន..." ផល់យប់ដែលនាងត្រូវត្រឡប់ចូលផ្ទះ ចួនជាពេលនោះមេឃងងឹត អ័ព្ទទឹកសទី ផ្គរគ្រហឹមគ្រាំៗ សន្ធឹងលើភ្នំគួរឲ្យខ្លាចចិត្ត តែសោភ័ក្ត្រ នៅតែទៅ ព្រោះដើរដិតផល់ផ្ទះអាចារ្យ ស្រាប់តែភ្លៀងធ្លាក់ខ្លាំងៗ មក ទទឹកអាវទាំងអស់ នាំឲ្យសោភ័ក្ត្រស្ទុះមកក្តៅចិត្តត្រឡប់មកផ្ទះវិញ ដោះ ខោអាវបោះបោលចូលដេកតែម្នាក់ប្រាថ្នានឹងឲ្យផល់ព្រឹកឆាប់ៗ

តែថៃជាដេកមិនលក់សោះសល់ខ្វល់ក្នុងចិត្ត  ប្រែចុះប្រែឡើងលើគ្រែចឹកដល់ណាផុតទន្ទ្រាន់តែឡាំងទៀតៗ ។ ដោយកំឡាំងចំណង់ចង់ជួបមុខនាងពេច  ក៏បន្ទាត់ចិត្តឲ្យអណ្តែតទៅតាមគ្រែសរនៃសេចក្តីស្រលៃ  គិតតែក្នុងប្រឌិតរឿងផ្សេងៗឲ្យបានជួបនឹងនាង  ឯរឿងនោះផ្សេងៗ  ប្លែកគ្នាតែត្រង់ទីកន្លែងពេលវេលា និងហេតុការណ៍ប៉ុណ្ណោះ ប្អូនតាំងផ្ទាល់ត្រូវជួយសង្គ្រោះម្តាយរបស់នាង  ហើយមាតារបស់នាងក៏លើកកូនស្រីឲ្យដោយសេចក្តីដឹងគុណ  ក្នុងជាបុរសកម្សត់បានជួយការពារជីវិតនាង  ឬមួយជាសោកក្រកម្សត់ .ដោយគំនាបសេចក្តីព្យាយាមនាងព្រមស្ម័គ្រជាមួយ  ឬក៏ជួលក្តៅដល់ទេវតាចុះមកបណ្តាលចិត្តនាងឲ្យស្រឡាញ់  ហើយបានជួយជ្រោមជ្រែងឲ្យសមដូចសេចក្តីប្រាថ្នា ។ល។

គិតណាស់ជាណាស់ទៅក៏ហែងដេកលក់  ទុកជាចំណេចក្នុងយ៉ាងណា  ក្នុងក៏មិនជិតស្និទ្ធិព្រលឹង  បណ្តាលឲ្យទៅជាក្តៅមុខខ្ទន់ក្បាលជាប្រចាំ  តែទៅគិតរឿងជាថ្មីតទៅទៀតក៏មិនកើត  ព្រោះខួរក្បាលចំពេញទាំងប៉ប្លែកកើតទៅហើយ  មិនមានកំឡាំងនឹងធ្វើការតទៅទៀតទោះបើយ៉ាងសោកក្រៅតែសៀមធ្វើក្នុងក្លុះៗ  កណ្តាលក្រោតស្ងាត់  ទឹកខ្ញុំញាណ សំលេងបម្រះទះទួលចុះឡើង  ចង់អណ្តែតសត្រូវផលចុះមកពីដេក  មិនឲ្យដេកឲ្យជៀសចេញឆ្ងាយ  ទើបប្រសិនជារូបធម៌នោះ

ប្រហែលប្រពោះជើរតែចង់ទៅហើយ តែនេះក្មេងមើលមិនឃើញក៏មិនដឹងធ្វើដូចម្តេច ។

លុះសន្សើមធ្លាក់ អាកាសត្រជាក់ល្អបរិវេណ លោកគ្រូក៏បានកន់ចូនក្បាលអស់កំឡាំងទន់ខ្លួនប្រាណ ត្របកភ្នែកបិទពុះមួយរំពេច ស្រមុកផ្សៀយរហូតដល់បែកបច្ចូសម័យ តែហល់ក្រោកឡើងក៏កើតឈឺក្បាលវិលមុខ រួយស្រពន់ម៉ស់ដៃជើងខានទៅថ្ងៃនាងអស់មួយថ្ងៃទៅទៀត ។

កាលបើរើសំបុត្រដាក់ក្រញ៉ាកស្បែកដើម្បីនឹងយកទៅចែកតាមផ្ទះ លោកគ្រូប្រទះសំបុត្រ ១ ច្បាប់ ខានស្លេខផ្ទះណាដនេត្រនារី ទើបប្រញាប់ប្រញាប់ចរលើយកសំបុត្រឯទៀតទៅដាក់សំណាក់អ្នកដទៃ ដើម្បីទុកពេលទំនេរជំអក់នៅលេងផ្ទះនាងឲ្យបានយូរបន្តិច ។ ប្រហែលជាម៉ោង ៩ លោកគ្រូបានដល់ខ្ទាផ្ទះនាងឃើញណាដនេត្រអង្គុយលើកៅអីនៅមុខផ្ទះកំពុងតាក់តាក ទើបឈរទ្រឹងសំឡឹងមើលតាកហ្ន៎យដោយសេចក្តីលើចខ្ទាំង ត្រាតែកាំងក្អកខ្លួនរំងាប់ខានទាញកណ្តឹងហៅម្ចាស់ផ្ទះ ប្អូនជានាងក្រឡេកមើលមកឃើញ នាងបានដើរចេញមកសាកសួរ "មានការអ្វី? អញ្ជើញចូលមក" ។

លោកគ្រូដើរចូលទៅទាញសំបុត្រហុចឲ្យនាង ណាដនេត្រមិនភ្លេចអរគុណដល់បុរសប្រៃសណីយ៍ រួចយកសំបុត្រចូលទៅក្នុងផ្ទះ មួយសន្ទុះបានចេញមកវិញ កាន់ក្រដាសមួយបន្ដោមនៅដៃ រួចនាងប្រស្រ័យ

រកសាក៏ក្រោកតបពាក្យដូច្នេះ “ យកផ្លែក្រៃបក ១ បន្ទោមទៅពិសាចុះ ក្រៃបកនេះផ្អែមល្អណាស់ ” ។

“ គុណជាជួរជួបមេត្តា បើខ្ញុំបាទទទួលពីដៃអ្នកក៏គន់ឆ្ងាញ់ពិសារវិញ សម្រាប់ខ្ញុំបាទ មួយវិញទៀត ផ្លែក្រៃបក ១ បន្ទោមនេះជារបស់មាន ដ៏ថ្លៃ ខ្ញុំបាទប្រហែលជាពុំហ៊ានទទួលទានទេ មុខជាទុកដាក់លក់មើល ហើយទេ” ។

នាងក៏ញញឹមឆ្លើយថា “អញ្ជើញពិសារចុះលោកប្អូន ! កុំឲ្យគេស៊ីកំ- ឡាំងពេក ព្រោះតែជាគេសន្សំយោងកំឡាំងម្យ៉ាងដែរ” ។

“ អរគុណអ្នកហើយ ខ្ញុំបាទពុំហ៊ានទទួលទានទេ ខ្ញុំបាទក្រែង ពេកគប់ដើម ចាំឲ្យស្មាយផ្លែក្រៃបកមួយបន្ទោមនេះ” ។

នាងក៏ទឹកកក់ចិត្តថា “គាត់នេះមិនព្រមញ៉ាំប្រែបគេសោះ” ចំណែក លោកក្រុមការ នានាការត្រឡប់ទៅកន្ទុះចិត្តវិញ តែងទទួលគាម ថ្លៃថ្នាំ អញ្ចាងពេលកំណត់ប្រែសារ ! ពេលនេះបានសាសង់ជាមួយ ដ៏ល្អ ! ទាំងបានទទួលក្រៃបក ១ បន្ទោមពីដៃនាងទៀត នេះ ជាជ័យជំនះដ៏ធំនៃការចូលរួមប្រកាសជាមួយនឹងនាង ។ កាលបើ លោកក្រុមគិតដល់រឿងនេះ រូបណាសាងត្រជាក់តែប្លែកឡើងដល់ចិត្ត ជាប់សិទ្ធិយើងសុខុម ។

បណ្ដាពួកយុវជនកំពុងពាល កាលៈបើយុវជនណាមួយបានស្គាល់សេចក្ដីកាមារម្មណ៍ជាគ្រាដំបូង រមែងជក់តាមភាពជាទីពេញចិត្តនោះ ដើម្បីនឹងនាំយកទាំងអស់ពីរបស់ ហើយនឹងនឹកសរសើរគុណនោះនូវរូបរាងលោមព័ណ៌របស់នាង ឬបណ្ដើរនូវប៉ះគេទាំងៗ ពេលម្នាក់ឯង រហូតដល់ប្រែងសរសេរកលល្អទីងនៃការបោះរបស់នាង តែមិនដឹងធ្វើម្ដេចនឹងបានជិតហាក់ដូចជាមានរបងអ៊ុមករាំងជាប់ មិនឲ្យឈានចូលក្នុងចក្រខ្សែដ៏ឧត្ដមបាន កាលបើចំណាប់ជិតគ្មានសង្ឃឹមដូចសេចក្ដីប្រាថ្នាហើយ គង់នឹងបានចងចាំច្បាស់នូវសេចក្ដីពិសិដ្ឋស្ងួតក្នុងចិត្តរបស់សោកក្ដៅ ទៅវេលានោះបានដោយឥតភាន់ច្រឡំ ។

ប៉ុន្តែសេចក្ដីរីករាយបែបនោះមិនស្ថិតស្ថេរប៉ុន្មានទេ ព្រោះសោកក្ដៅមានឋានៈជាកញ្ញា ហើយថែមទាំងមិនមានញាតិសន្តានជិតខាងផងផុតផ្ដេសផ្ដាស ។ ចំណែកនាងពេលដែលកំពុងរៀន នាងមិនដែលសំដែងទឹកចិត្តរបស់ខ្លួនឲ្យឃើញថា នាងគេតែនឹងសោកក្ដៅនោះឡើយ គិតតែអំពីរៀនសូត្រដោយយកចិត្តទុកដាក់ អាការៈជាកុមារីដ៏ឆាប់ប្រែងរៀន ទៀងត្រង់យ៉ាងប្រសើរក្រៃលែងបំផុតក្រៃលែង ។ នាងចេកដៃផ្កាស្រក់ដៃពាក់មកលើមុខខ្ញុំ ។ សក់នោះជាត់ជាយតាមខ្យល់ចុះពន្លឺប្រាក់នៃចន្ទ្រាដ៏អស្ចារ្យផ្ទុករូបនេះ នាំឲ្យសោកក្ដៅនឹកឃើញថានេះជាក់ជាទេពធីតាច្បាស់ចុះមកដែនដីតែម្ដងហើយ ។

ហើយសោកក្រៃពីនឹកគិតថា ខ្លួនជាមនុស្សព្រោកពាចមិនសមស័ក្តិ នឹងនាងនោះ ទើបចូលរួមរៀបនឹងនាងផងពុំបាន ទុកជាខ្លួនអង្គុយនៅជិតនាងក្តី ក៏ដូចជាឆ្ងាយទៅដែរ ព្រោះគ្មានឱកាសនៅរំលស់សាកសួរអំពីរឿងស្នេហ៍នោះ សូមអង្វរប្រគល់តែម្នាក់ឯងនេះឲ្យទឹកសេចក្តីអន្ទះបានផល់រូបអីម្ល៉េះ! ប្អូនក៏តាំងចិត្តថា នឹងលែងមករកហើតហេតុតទៀត ព្រោះគួរឲ្យអា-ម៉ាស់មុខពេកណាស់ ទុកជាមកទៀតៗ ទៅក៏គ្មានផលអ្វី ពើនាងហាក់ដូចជាព្រោះដើយករើយព្រើយ ៗបែបនេះ ពុំទាន់ចិត្តស្រទាប់ទ្ទីបទៅក្រែងលោនាងអាណិតអាសូរខ្លះ ព្រោះចិត្តអកក់ស្រឡាញ់គេ រមែងមានសេចក្តីសង្ឃឹមជាដរាប តែម្តុះសោកក្រៃគាន់តែស្រងូតស្រងាត់ឡើងជាលំដាប់ ។

ថ្ងៃមួយជាពេលល្ងាចគ្រាខ្លួន នាងបានបោលកែវដៃមកសោកក្រៃម្នងៗដែរ តែភ្នែកទៅរាំងគូនោះទុកជាមុខពារក្បះដល់ធ្វើយប្រមាត់សោកក្រៃដូចព្រួចក្តី សើងសំដែងខ្លួនសេចក្តីបរិសុទ្ធចិត្តទាំងអស់ ធ្លាក់ចុះលើសោកក្រៃបីដូចបញ្ចេញមកអំពីទឹកលាលហាល ។ ឯទឹកនេះទ្រុងទាំងគូនោះបានស្រោចស្នានចិត្តឲ្យត្រេកអរតួហោយចុកអម្រឹតជ្រែជាក់ បានសុះដល់ខ្សែក្រូងក្ដីស្ញោណាទ្ឋកង់ពេកញ្ញាបញ្ចូរនក់ ទៅយើងពលគ្នាជាពិណៈ១ដើរលេសហា! ហេតុរបៀស្រខ្យល់ស្រសៀកមកក៏ធ្វើយនំគោរមស្ទ្រាម ។ ចំណែកសោកក្រៃក៏ពុំហានសំឡឹងនាងចំដែរ តែយប់មួយផ្ទាយគារស្រទៃ

ក៏ក្រេបខ្លួនសំឡឹងមើលនាងយ៉ាងយូរ រហូតដល់នាងឡើងមុខក្រហមគេច
ចេញ ព្រោះសេចក្ដីអៀនហើយនាងបែរខ្នងឲ្យ ។

នៅវេលានោះ លោកគ្រូតូបចិត្តផ្សែតខ្លួនធ្វើឲ្យធ្លាក់ធ្លងទៅលើនាង
ហើយយកដៃទះថ្ពាល់ផាំងក្អាក់ដល់នាងព្រមទាំងអាចារ្យ តែលោកគ្រូមិន
បានជាតបក្ដីព្រោះអស់ចិត្តណាស់ចង់តែយំ យកដៃទាំងពីរខ្ទប់មុខផង
ទុក្ខសញ្ចប់សញ្ចឹងដោយសេចក្ដីតក់ស្លុតស្ងៀម នេះច្បាស់ជាណុដនេត្រមិន
អាណិតដល់ប្រុងលោកគ្រូសោះ បានជាបែរខ្នងធ្វើព្រងើយ ខណុដ
នេត្រនារីអើយ! រូបខ្ញុំអាក្រក់ណាស់ណាទៅឬ? បានជានាងធ្វើជូរបេះ
ទុកថ្ងៃនេះទៅ សមខ្ញុំសោះសូន្យផុតសប្បាយរីករាយ ណាព្រាត់
ប្រាសចាកនុកក្ដាយបង់បូន បានឃើញមុខណុដនេត្រគ្រាន់បាន
ស្បើយទុក្ខខ្លះ សូមនាងធ្វើយើយថែមទៀតត្រូវឲ្យលោកគ្រូឈឺចិត្តទេ ។

កាលបើឈ្មក់កន្សែងការខ្ទឹកកំពឹងដល់សេចក្ដីទុក្ខនាពេលនោះ លោក-
គ្រូមិនបានឮពាក្យអាចារ្យសួរ រហូតដល់អាចារ្យគោរផ្ទូនពាក្យជាំ
គំរប់ ៣ លើកទើបបានឮ ងើបមុខឡើងមុខនោះជោគទៅដោយទឹក
ភ្នែក លោកគ្រូនឹកស្មានថាខ្លួនស្រមៃ ហើយយកចុងទ្រនៃដៃជូតភ្នែកឲ្យស្អាត
អាចារ្យឃើញដូច្នោះក៏សួរថា "ព្រើយលោកគ្រូ ឯងកុំព្រួយអ្វី
ខ្ញុំជាងនេះយំលោកយ៉ាងណា ១ក្ដី ក៏ការណ៍នេះកន្លងហួសទៅហើយ ធ្វើ
ម្ដេចកុសលផលបុណ្យរបស់ឯងត្រូវឲ្យកំព្រាដូច្នេះ" ។ (មានត)

ឃាតកសហស្រភាគ

ប្រជុំរឿងប្រលោមលោក (ដារឿងកើប)

ភាគទី ១០

ក្រុងនិពន្ធស្រី ញ៉ុក-ថែម ប្រែចេញពីភាសាបារាំងដែលនិពន្ធដោយ...

# រឿងអ្នកប្រមាញ់ ៣ នាក់ជាមិត្តស្លាប់

(តពី)

គ្រាន់តែខ្ញុំកាយដីលុបរួចស្រេច ចោលតែក្រឡេកមើលទៅត្រើយម្ខាងខាយ ស្រាប់តែឃើញខ្ទមគាត់ ៗ ហើយ បើកសំដៅមករកកោះនោះដើម្បីនឹងមកចុះយកទឹកនៅក្នុងនោះ ឱ្យគេទូរប់ទៅដាក់ផ្ទះសម្បុរនិងញ ៗ គ្រានោះ ចិត្តខ្ញុំបេះដូងញ័រគិតនឹងតែកំពើ ដែលខ្ញុំបានធ្វើមកនោះមិនដាច់ ហើយកើតគំនិតគិតឃើញថា "ប្រសិនបើហ្វ្រាញខ្ញុំឱ្យគេឃើញ មុខជាគាត់ចាប់ឱ្យពួកគាត់ចាប់ខ្ញុំសម្លាប់ចោលមិនខាន នៅវេលាដែលគាត់យកថាខ្ញុំជាអ្នកសម្លាប់កូនគាត់ បើខ្ញុំជាខ្ញុំបេះទឹកយ៉ាងណា ក៏គង់តែមិនសមស្រម៉ុក ៗ ដូច្នេះគួរតែខ្ញុំគេចខ្លួនចេញទៅសិនឱ្យផុតពីសេចក្ដីអាយ ផុតពីបុរាណរបស់គាត់ទៅសិន ព្រោះរឿងកូនស្លាប់នោះមុខជាគាត់ផ្ទេរមកលើខ្ញុំមិនស្រេច" ៗ នៅជិតក្បែរកន្លែងនោះ មានដើមឈើ ១ ដើមធំ ហើយមានស្លឹកក្រសុំត្រសាយសាខាល្មមបាំងខ្លួនខ្ញុំឱ្យជិតបាន ហើយខ្ញុំចាប់ផ្ដើមឡើងដើម

ឈើនោះ ហើយលាក់ខ្លួនពួននៅថែគាបឈើ ។ ល្មមខ្ញុំមើលទៅកាន់ក្រោមឃើញអ្វីៗ បានច្បាស់ ខ្ញុំបានឃើញទូកនោះពួលមកចតត្រង់កន្លែងដែលចតពីមុននោះឯង ។

តាចាស់និងពួកចោរ នាំគ្នាឡើងពីទូកស្រេះទៅមួយរំពេច ហើយដើរសំដៅទៅត្រង់កន្លែងកប់ដី ខ្ញុំសង្កេតមើលទឹកមុខផងតាំងនោះឃើញស្រស់បស់ទាំងអស់គ្នា ដោយមានសង្ឃឹមពេញទី ប៉ុន្តែដល់ឃើញមានភ្នាមកកាយខឹងល្អុបទៅវិញថ្មីៗ ក៏ផ្លាស់ទឹកមុខមួយរំពេច ទាំងតាចាស់ទាំងពួកចោរ ។ ពួកមនុស្សទាំងនោះ នាំគ្នាកាយដីទាំងលើកថ្មគំរបនោះចេញហើយក៏ចុះស្រះទៅ រួចស្រែកហៅឈ្មោះគ្នាកំឡោះនោះមិនឮសូរមាត់ឆ្លើយសោះ ហើយនាំគ្នាដើរចូលទៅក្នុងទៅ ស្រាប់តែឃើញដេកស្រងាត់នៅលើគ្រែហើយមានទាំងកាំបិតដោតជាប់ត្រង់កំពូលបេះដូង ព្រោះខ្ញុំមិនបានដកយកកាំបិតនោះចេញមក ។ ពួកមនុស្សទាំងនោះក៏ស្រែកទ្រហោយំកងរំពងឡើង តាចាស់ក៏ដួលសន្លប់ដោយសេចក្ដីសោកសោកយ៉ាងលើសលុប ពួកចោរៗ ក៏នាំគ្នាត្រាប់ត្រកងលើកគាត់ចេញមកដាក់លើកន្ទេលអាកាសស្អួ ហើយសែងគាត់មកដាក់ក្បែរគល់ឈើ ដែលខ្ញុំពួននៅពីខាងលើនោះឯង ។ ទុកជាពួកចោរទាំងនោះយ៉ាងណា តាចាស់ក៏នៅតែសន្លប់ដដែល មុខគួរឲ្យអាណោចអធ័មអាណិត

តាចាស់ជាឪពុកពន់ពេក គាត់នៅតែសន្ទប់ជាច្រើនម៉ោងស្ទើរតែអស់សង្ឃឹមទៅហើយ ។

លុះគាត់សន្ទប់ជាយូរដូច្នោះហើយ ក៏ត្រឡប់ដឹងខ្លួនមានស្មារតីឡើងវិញ ទើបពួកបារាំងនាំគ្នាយកសំពត់យ៉ាងល្អៗ ស្រោបកូននោះលើកចេញមក ក្រោយដែលបានដករណ្ដៅរួចស្រេចហើយ ក៏ដាក់សពគ្រឿងទៅក្នុងរណ្ដៅនោះទៅ ។ ឯតាចាស់ជាឪពុកបានបារាំងពីរនាក់ជួយទប់ទ្រខ្លួនគាត់ មុខគាត់មានទឹកភ្នែកហូរហោរមយំខ្សឹកខ្សួល មុខគួរឲ្យអាណោចអធ័មណាស់ គាត់ចំប្រឹងចាប់បោះដុំដីទៅក្នុងរណ្ដៅបានបន្តិច ហើយពួកបារាំងក៏នាំគ្នាកាយដីលុបរណ្ដៅនោះទៅ ។

កាលពួកបារាំងដឹកកប់សពកូនតាចាស់រួចហើយ ក៏នាំគ្នាដឹកជញ្ជូនយកគ្រឿងប្រដាប់ប្រដាចេញមកពីក្នុងដី ព្រមទាំងគ្រឿងស្បៀងអាហារដែលសេសសល់នៅតាំពីប៉ុន្មាន យកទៅដាក់ទូកទាំងអស់ ។ ឯតាចាស់ក៏បេះតែខ្សឹកខ្សួលយំសោកស្ដុកស្ដាញជាពន្ទឹក ទប់ខ្លួនពុំណោះមិនជាប់ ដើរមិនរួច ទើបពួកបារាំងលើកគាត់ផ្ដេកលើគ្រែស្នែងរួចនាំគ្នាសែងចុះទូក ហើយបើកគ្រឿងចេញទូកទៅ ។ មិនយូរប៉ុន្មាន ទូកនោះក៏ចេញឃ្លាតឆ្ងាយពីកោះទៅ ទាល់តែខ្ញុំលែងមើលឃើញតទៅទៀត ។

លុះតាចាស់និងពួកបារាំងចេញផុតទៅហើយ ខ្ញុំក៏នៅលើកោះនោះតែម្នាក់ឯង វេលាយប់ខ្ញុំចូលទៅជ្រកអាស្រ័យនៅក្នុងរូងដីដែលនោះឯង

ដល់វេលាថ្ងៃ ខ្ញុំក៏ចេញទៅដើរលេងនៅជុំវិញកោះ ហើយឈប់ដើរលេង
នៅក្បែរគល់ឈើដែលខ្ញុំត្រូវកបប់សព្រោក ។

ខ្ញុំមានសេចក្តីអផ្សុកណាស់ ដែលនៅលើកោះនោះតែម្នាក់ឯង អស់
វេលាយូរដល់ទៅ ៣ ខែ តែគតពីនោះមក ខ្ញុំបានឃើញទឹកសមុទ្រស្រក
ស្រកចុះទៅយ៉ាងសំមើម ហើយទីកោះដែលខ្ញុំអាស្រ័យនៅ ក៏ទៅជាកោះ
យ៉ាងធំ ហើយហាក់ដូចជានៅជិតនឹងត្រើយដីគោក តាំងមានចំនួនផ្លូវ
ដើរឆ្លងកាត់ទៅកាន់ត្រើយដីគោកបានផង ទើបខ្ញុំចេញដើរជាវេលាយូរ
ណាស់តាមឆ្នេរសមុទ្រ ដែលដាច់សទៅដោយគតខ្សាច់ ខ្ញុំអស់កំឡាំង
ណាស់ស្ទើរតែដើរទៅទៀតមិនបាន តែនៅទីបំផុត ខ្ញុំក៏ដើរទៅដល់ត្រើយ
ដីគោកបាន នៅវេលានោះខ្ញុំចោលភ្នែកក្រឡេកមើលទៅទិសខាងពី
ខាងមុខខ្ញុំ នោះឃើញហាក់ដូចមានភ្លើង ១ ធំនៅឆ្ងាយលន្លឺមជាហេតុនាំ
ឲ្យខ្ញុំមានសេចក្តីត្រេកអរ ដោយនឹកសង្ឃឹមថា "ខ្ញុំមុខជាបានជួបប្រទះ
នឹងអ្នកណាមួយមិនខាន ទើបមានគេដុតភ្លើងឡើងដូច្នេះ" ។ ប៉ុន្តែដល់ខ្ញុំ
ដើរចូលទៅកាន់តែជិតទៅ ការនឹកស្មានរបស់ខ្ញុំខុសស្រឡះ គឺដែលខ្ញុំ
នឹកស្មានថាជាភ្លើងនោះមិនមែនសោះ ត្រឡប់ទៅជាប្រាសាទខ្ទន់ដែន
ក្រហមឆ្អៅ ដែលត្រូវនឹងរះថ្ងៃចាំងមក មើលទៅពីចម្ងាយហាក់ដូចជា
អណ្តាតភ្លើង ។

ខ្ញុំក៏ដើរចូលទៅឈប់សម្រាកកម្លាំង ហើយអង្គុយនៅក្បែរប្រា-សាទនោះឯងពិនិត្យមើលរបៀបគេសាង ខ្ញុំកំពុងគិតពិចារណាមើលគេហ-ស្ថានជីស្រុកស្តូបនោះ មិនទាន់ជាអស់ចិត្តបានផង ស្រាប់តែឃើញមនុស្សប្រហែល ១០ នាក់ រូបរាងមាំសាច់ស្ពាភាពទើបនឹងត្រឡប់មកពីដើរលេង ៗ ប៉ុន្តែហេតុដែលនាំឲ្យខ្ញុំនឹកឆ្ងល់ណាស់នោះ គឺអ្នកទាំងនោះ សុទ្ធតែម្នាក់ៗកាន់ស្លាបព្រាម្នាក់ទាំងអស់គ្នា ៗ ផងទាំងនោះ ដើរមកជាមួយនឹងការរស់ម្នាក់ មានរូបរាងធំខ្ពស់ មានមុខមាត់ជាទីគោរព ៗ

ខ្ញុំរឹតតែមិនចេះនឹងឆ្ងល់មិនដាច់ អំពីការប្រព្រឹត្តិនៃមនុស្សម្នាក់ច្រើននាក់ព្រមគ្នា ហើយសុទ្ធតែរូបរៀកមានកាក់ជួបគ្នាទាំងអស់ ៗ នៅវេលាដែលខ្ញុំកំពុងតែគិតគំនុំរកហេតុផលនោះ ស្រាប់តែផងទាំងនោះនាំគ្នាដើរត្រសងចូលមករកខ្ញុំ ហើយសំដែងសេចក្តីគោរពដែលបានមកចប្រព្រឹត្តិនឹងខ្ញុំ លុះរកកាត់នឹងខ្ញុំរួចហើយក៏សួរមកកាន់ខ្ញុំ អំពីដំណើរទំនងដែលបាននាំខ្ញុំមកកាន់ទីនោះ ៗ មុននឹងដំណាលរឿងរ៉ាវរបស់ខ្ញុំ ៗ សុំឲ្យអ្នកទាំងនោះអង្គុយសិន បានខ្ញុំដំណាលរឿងដែលជាទីពេញចិត្តឲ្យស្តាប់ ព្រោះរឿងរ៉ាវរបស់ខ្ញុំគួរការពេលវេលាវែងបន្តិច ទើបបានថ្លែងចប់សព្វគ្រប់បាន ៗ អ្នកទាំងនោះ ក៏នាំគ្នាអង្គុយដោយស្ងប់ស្ងួន ហើយៈទើបខ្ញុំក៏ចាប់ផ្តើមនិយាយរឿងរ៉ាវ តាំងអំពីខ្ញុំចេញចោលនគរហ្លួង

បានមកដល់ទីនោះ   រឿងរបស់ខ្ញុំនេះនាំឲ្យស្រុកតាំងនោះ   មានសេចក្តីងឿងឆ្ងល់ពន់ពេកណាស់ ។

លុះខ្ញុំពណ៌នារឿងការរបស់ខ្ញុំចប់សព្វគ្រប់ហើយ   ទើបបុរសកំឡោះតាំងនោះក៏និយាយសូមឲ្យខ្ញុំចូលទៅក្នុងប្រាសាទជាមួយនឹងគេ ។ ខ្ញុំក៏ទទួលពេញចិត្តព្រមចូលទៅ   យើងក៏នាំគ្នាដើរកាត់ថែវល្វែងទទួលភ្ញៀវ និងល្វែងតូច-ធំ និងបន្ទប់ដែលសុទ្ធតែមានគ្រឿងប្រដាប់ផ្ទះ ទើបបានដល់ទៅក្នុងបន្ទប់ធំ ១ ដែលមានតាំងកៅអីវែង ១០ ក្រាលព្រំពណ៌ខៀវដាក់តំរៀបជារង្វង់មូល ។   ហើយនៅឃ្លាត ៗ ពីគ្នាបន្តិច   ជាកៅអីសម្រាប់អង្គុយក្នុងវេលាថ្ងៃក៏បាន   សម្រាប់ដេកក្នុងវេលាយប់ក៏បាន   នៅត្រង់កណ្តាលរង្វង់នោះមានកៅអី ១ ទៀត   ដាក់របៀប ១០ ខុសបន្តិច   ជាអាសនៈរបស់ព្រឹទ្ធាចារ្យដែលយើងបានពោលរួចមកហើយ   ឯបុរសកំឡោះឯទៀតៗ ក៏អង្គុយលើកៅអីតាំង ១០ នោះ ។

ដោយហេតុកៅអីតាំងនោះ   អង្គុយបានតែម្នាក់ៗ ប៉ុណ្ណោះ   បានជាមានជនកម្លោះម្នាក់   ក្នុងចំណោមជនតាំងនោះនិយាយឡើងប្រាប់ខ្ញុំថា ម៉ែនសម្លាញ់! ចូរអ្នកឯងអង្គុយត្រង់កណ្តាលព្រំនេះចុះ   យើងសុំប្រាប់អ្នកថា សូមឲ្យអ្នកគ្រាន់តែមើលយើងបានហើយ   កុំចង់ដឹងឲ្យហួសពីនោះទៅទៀត   អំពីហេតុដែលយើងខ្វាក់ភ្នែកស្តាំទាំងអស់គ្នា   គឺថាសុំឲ្យអ្នកសុខចិត្តត្រឹមតែមើលបានហើយ   កុំចង់ដឹងការអ្វីឲ្យហួសពីនោះទៅទៀត ។

ឯតាចាស់អង្គុយនៅ ១ ស្របក់ គាត់ក៏ក្រោកឡើងហើយដើរចេញទៅ ហើយត្រឡប់មកវិញមួយរំពេច នាំយកចានអាហារសម្រាប់ឧត្តម-ជនទាំង ១០ នាក់ ហើយគាត់ក៏ចែកអាហារ ១ ចំណែកម្នាក់ៗគ្រប់គ្នា ។ ឯខ្លួនខ្ញុំគាត់ក៏បានឲ្យ ១ ចំណែកដែរ ហើយខ្ញុំនិងអ្នកទាំងនោះក៏នាំគ្នាបរិភោគទៅ លុះបរិភោគរួចហើយ តាចាស់ដដែលនោះគាត់ចាក់ស្រាឲ្យម្នាក់ ១ ពែងៗគ្រប់គ្នា ។

ដោយរឿងរ៉ាវរបស់ខ្ញុំជាចំឡែកពេកណាស់ បានជាអ្នកទាំងនោះសូមឲ្យខ្ញុំនិយាយរឿងនោះម្ដងទៀត ក្រោយបរិភោគអាហារល្ងាចរួចហើយ ខ្ញុំក៏តាំងពណ៌នារឿងដែលទាល់តែយប់ជ្រៅទៅច្រើន គឺជាមួយយប់ធំទើបចប់រឿងរបស់ខ្ញុំ ។ ពេលនោះមានឧត្តមជនម្នាក់និយាយក្រែកឡើងប្រាប់ទៅតាចាស់នោះថា "តាឃើញទេ, ដល់ពេលដេកហើយ តានៅមិនទាន់ចែករបស់អ្វី ដែលយើងតែងធ្វើមកឲ្យយើងនៅឡើយ" ។ លុះឮពាក្យនេះ តាចាស់ក៏ក្រោកឡើងដើរទៅកន្លែងបន្ទប់ ១ ស្រាប់តែចេញមកវិញឃើញកាន់ចូលជើង ១០ ដាក់តម្រួតៗលើគ្នា សុទ្ធតែជាជើងទៀនគ្របដោយសំពត់ពណ៌ខៀវទាំងអស់ ហើយគាត់ដាក់ជើងទៀនមួយៗ នៅពីខាងមុខឧត្តមជនទាំងនោះ ម្នាក់មួយៗ គ្រប់គ្នាព្រមទាំងចន្ទុះមួយៗផង ។

អ្នកតាំងនោះក៏គាំងបើកត្របកភ្នែកឡើង ឃើញមានសុទ្ធតែផ្ទះ មេឃ្រាំ ត្បូង និងលំហខៀវតាណារលើប ហើយគាំងលាយច្របល់របស់តាំងនោះជាមួយគ្នា រួចគាំងយកមកផ្ទុះលាបស្រមុកខ្ទង់មុខមាត់ស្រមេម ស្រមាមឲ្យគាក់មើលណាស់ ។ លុះបានប្រឡាក់ឲ្យខៀវយង់ផ្តួច្បោះហើយ អ្នកតាំងនោះ ក៏គាំងដៃស្រែកយំខ្សឹកខ្សួលឡើងតាំងអស់គ្នា ហើយខ្ទះគប់មុខខាត់គក់ទ្រូងរបស់ខ្លួន គាំងស្រែកមិនឈប់មាត់ថា "នេះឯងហើយ ជាផលនៃការនៅទំនេរទីឯការប្រព្រឹត្តខ្ជិលច្រអូសរបស់យើង" ។

ជនតាំងនោះ គាំងនាំគ្នាធ្វើការហ៊ោកប់ខ្សែកដួចបេះ ស្ទើរតែអស់មួយយប់នោះ ទាល់តែអស់ចិត្តហើយទើបនាំគ្នាឈប់ រួចគាបាស់ក៏យកទឹកមកឲ្យអ្នកតាំងនោះលាងមុខលាងដៃចេញ តាំងសំពត់អាវក៏ប្រឡាក់ខ្ចូចអស់ គោរដ៏ផ្លាស់ពោលទៅ យកសំពត់ផ្សេងទៀតមកស្លៀកពាក់ ។ ការដែលអស្ចារ្យបំផុតនេះ ខ្ញុំទើបតែចិន្តបានឃើញក្នុងគ្រានេះឯងជាដំបូង គាំងពីកើតមកខ្ញុំមិនដែលឃើញទារណាប្រព្រឹត្តអំពើដូចជាឆ្កួតលលាដូច្នេះទេ ។

អ្នកស្រី, សូមឲ្យអ្នកគិតមើលចុះ ខ្លួនខ្ញុំដែលត្រូវគេយាក់ឲ្យនៅស្មៀមក្នុងទីនោះ តើខ្ញុំគឺងទ្រាំយ៉ាងណាទៅ! ។ ខ្ញុំស្ទើរតែហាមាត់សួរទៅតាំងនោះ តាំងពាន់ដង តែក្នុងគ្រួមជនតាំងនោះ បង្គាប់ឲ្យខ្ញុំនៅ

តែប្រៀបតាមពាក្យប្ដូជា ខ្ញុំត្រូវតែនាំទៅដូចជារូបតុក្កតាប្រុសមួយយ៉ាងដំណោះ ។

ដល់ថ្ងៃស្អែកតមក យើងនាំគ្នាក្រោកពីព្រឹកដើរចេញទៅយកខ្យល់អាកាស ហើយខ្ញុំបាននិយាយទៅនឹងអ្នកតាំងនោះថា "លោកម្ចាស់ថ្លៃ, ខ្ញុំសូមជំរាបអស់លោកថា ខ្ញុំសូមលើកលែងកាន់ច្បាប់ជីគីងតែង ដែលបញ្ញត្តឲ្យខ្ញុំប្រតិបត្តិតាមពីថ្ងៃល្ងាចម្សិលនោះហើយ ដ្បិតខ្ញុំមិនអាចប្រតិបត្តិតាមបានទេ ។ ខ្ញុំយល់ថាអស់លោកសុទ្ធតែជាសុភាពបុរស ហើយមានសតិបញ្ញាធំទូលាយ អស់លោកក៏ល្អស្គាល់ទុកចិត្តខ្ញុំហើយ ប៉ុន្តែខ្ញុំបានឃើញអស់លោកធ្វើអំពើប្លែកពីអ្នកដទៃ ។ មានតែមនុស្សឆ្កួតលលាទើបអាចធ្វើដូច្នោះបាន ទុកជាគេនៅក្រោះថ្នាក់ដល់ខ្លួនខ្ញុំដូចម្ដេច ក៏ខ្ញុំនឹងយកទ្រាំតាមទស្សនៈអស់លោកមិនបានទេ ខ្ញុំត្រូវតែសុំសួរអស់លោកថា ហេតុអ្វីបានជាអស់លោកយកដេះមេព្រៃវ្សង ទឹកល័ក្ខមកលាយលាបប្រឡាក់មុខមាត់ដូច្នោះ? ហើយហេតុម្ដេចបានជាអស់លោកមានតែក្អកម្នាក់ទាំងអស់គ្នា ហេតុនេះ ខ្ញុំសូមអង្វរអស់លោកឲ្យជួយបំពេញបំណងចង់ដឹងនេះឲ្យបាន" ។ ទុកជាខ្ញុំខំប្រឹងសួរយ៉ាងណា អ្នកតាំងនោះនៅតែមិនឆ្លើយសោះ ទាំងមិនមើលមកខ្ញុំផង ទើបត្រូវតែខ្ញុំបិទមាត់នៅស្ងៀមតទៅទៀត ។

វេលាថ្ងៃមិនមានអ្វីជាចំណែកខ្លួនសពីជម្ពូការៈ ១ ថ្ងៃកន្លងបន្តទៅ, ហើយតែកាលណាដល់វេលាយប់ ព្រះយេស៊ូវបរិភោគអាហារមួយស្របទៀនខ្លួនហើយ គាត់ក៏យកដើមពីណាខ្លះទាំងនោះមកទៀត រួចប្រគល់ខ្ញុំ-ជនទាំងនោះ ក៏តាំងលោបប្រចណ្ឌក់មុខខាត់តាំងស្រែកឡើងថា "នេះហើយជាផលនៃការទៅទំនេររបស់យើង និងការដើរលេងឡើយជួយរបស់យើង" ។

នៅទីបំផុត ខ្ញុំមិនអាចទប់ចំណង់បង់ជីវិតរបស់ខ្ញុំតទៅទៀតបាន ទើបខ្ញុំសុំអង្វរទុកមុជនតាំងនោះយ៉ាងអ៊ុំមាត់ ថ្វីបើពុំព្រមប្រាប់ទេ ក៏សូមឲ្យអស់លោកទាំងនោះពន្យល់ផ្លូវ ដើម្បីឲ្យខ្ញុំបានវិលត្រឡប់ទៅនគររបស់ខ្ញុំវិញ ព្រោះខ្ញុំមិនអាចទ្រាំត្រូវនៅរួមជាមួយនឹងអស់លោកឲ្យបានយូរតទៅទៀតទេ ដោយខ្ញុំមិនអាចទ្រាំមើលការចំឡែកអស្ចារ្យរបស់ព្រះពល់ ។ យប់បានតទៅទៀតដោយមិនព្រមអនុញ្ញាតឲ្យខ្ញុំបានជឿរឿងអ្វីឡើយ ។

ខណៈនោះ ទុកមជនម្នាក់ឆ្លើយតបមកខ្ញុំជំនួសអ្នកទាំងពួងថា "កុំបីអ្នកជឿនិងឆ្ងល់អ្វី និងសេចក្ដីប្រព្រឹត្តរបស់យើងនេះ ដែលយើងមិនព្រមទទួលអង្គអ្នក រហូតមកដល់វេលានេះដោយហេតុតែយើងករុ-ណាតមេត្តាចំពោះរូបអ្នក ហើយជួយអ្នកឲ្យរួចផុតពីទុក្ខសោកគ្រោះថ្នាក់ដូចអ្នកបានឃើញយើងកល់គ្នានឹងនៃតុកស្រាប់ ។ ប្រសិនបើអ្នកនៅតែទទួចបន្ទំជីន ព្រោះជាក់អកុសលរបស់យើងទៀត សុំឲ្យអ្នកនិយាយពតបុះ

យើងនឹងបំពេញចំណង់អ្នកតាមដែលអ្នកសុំយើងសព្វថ្ងៃនេះក៏បាន" ។ ហើយខ្ញុំនិយាយប្រាប់ទៅវិញថា ខ្ញុំមិនមានសេចក្ដីហេតុដេកអ្នកទាំងអស់ៗ ។ ខ្មោចដដែលនោះនិយាយម្ដងទៀតថា "យើងនឹងឲ្យទានអ្នកឯង ឲ្យសមនឹងការបាត់បង់ជើងរបស់អ្នក គឺត្រូវធ្វើអ្នកឲ្យខ្វាក់ភ្នែកស្ដាំម្ខាង ក្លួចណាំយ៉ាងដែរ" ។ ខ្ញុំតបទៅវិញថា មិនអីទេ ខ្ញុំសុំជំរាបអស់លោកថា ប្រសិនបើគ្រោះថ្នាក់នេះ ធ្លាក់មកដល់ខ្លួនខ្ញុំ ៗ មិនបន្ទោសអស់លោកទេ ហើយខ្ញុំទទួលខុសដោយខ្លួនឯង" ។ ខ្ញុំថ្លែងសេចក្ដីម្ដងទៀតថា កាលណា ខ្ញុំខ្វាក់ភ្នែកម្ខាងទៅ ខ្ញុំមិនមានសង្ស័យថា ត្រូវបានទៅជាមួយនឹងអស់លោកទេ តាមដែលខ្ញុំគិតស្មាន ពីព្រោះចំនួនអស់លោកនៅពេញកន្លែងទៅហើយ ទាំងមិនអាចបន្ថែមឲ្យលើសចំនួនទៀតផង ។ ខ្ញុំប្រាប់ទៅអ្នកទាំងនោះថា ខ្ញុំសុខចិត្តតែនៅរួមជាមួយនឹងមនុស្សល្អគ្រប់រូបជាអ្នកទាំងនោះដែរ ប៉ុន្តែបើហៅយកានមិនបាន ត្រូវនៅបែកគ្នាវិញ នោះត្រូវធ្វើតាមឲ្យតាមសេចក្ដីសុំរបស់ខ្ញុំវិញចុះ ។

ខ្មោចទាំង ១០ នាក់ លុះឃើញថាខ្ញុំតាំងចិត្តដាច់ហើយស្ងប់ស្ងៀមអ្វីហើយ គឺចាប់យកសត្វចៀម ១ មកចាក់កសម្លាប់ កាត់ខ្ទុះស្បែកចេញ ហើយគឺយកកាំបិតដែលប្រើការនោះមកបង្ហាញខ្ញុំ ហើយប្រាប់ថា "ចូរអ្នកឯងយកកាំបិតនេះទៅប្រើការ ក្នុងកាលដែលយើងនិយាយប្រាប់អ្នកក្នុងកាលសព្វថ្ងៃនេះឯង ។ ត្រូវយើងខ្ញុំរុំខ្លួនអ្នកនឹងស្បែកនេះហើយ

យើងដេរភ្ជាប់ រួចយើងទុកអ្នកចោលនៅកន្លែងនេះ ហើយយើងនាំគ្នាថយចេញទៅ ។ មួយស្របក់ទៀតមានសត្វស្លាប ១ ជាសត្វមានរូបកាយធំសំបើម ដែលគេហៅថា សត្វរុក (ឥន្ទ្រី ?) ហើរមកលើអាកាស ហើយឆាបចាប់អ្នកឯងដោយសំគាល់ថាជាសត្វចៀម រួចនាំអ្នកឡើងទៅឯអាកាស, តែយើងសុំកុំឲ្យអ្នកភិតភ័យតក់ស្លុតឲ្យសោះ សត្វនោះនឹងនាំអ្នកចុះទៅឯផែនដីវិញ ហើយនឹងដាក់អ្នកនៅលើកំពូលភ្នំណាមួយ ។ តែកាលបើអ្នកដឹងថាគេដាក់ដល់ដីហើយ ចូរអ្នកយកកាំបិតវះស្បែកចៀមហើយអ្នកចេញមកក្រៅទៅ ។ ឯសត្វឥន្ទ្រីគ្រាន់តែក្រឡេកឃើញអ្នកភ្លាម ក៏នឹងភិតភ័យហើរចេញទៅ ទុកឲ្យអ្នកនៅទីនោះតែម្នាក់ឯង ។ អ្នកកុំឈប់នៅត្រឹមទីនោះ ចូរអ្នកដើរតទៅទៀតដរាបទាល់ដល់ប្រាសាទ ១ មានទំហំធំសំបើមអស្ចារ្យ មានដំបូលប្រក់សុទ្ធតែក្បឿងមាសជាប្រាសាទប្រដាប់ដោយត្បូងមរកតធំៗ នឹងពេជ្រចំរុះគ្រាប់ធំៗ ទៀតជាច្រើន ។ ចូរអ្នកទៅឯទ្វារ ដែលតែងតែបើកចំហជានិច្ចហើយអ្នកដើរចូលទៅ ។ ពួកយើងដែលបាននៅក្នុងប្រាសាទនេះទាំងប៉ុន្មាន សុទ្ធតែធ្លាប់បាននៅក្នុងទីនោះមកហើយគ្រប់ៗគ្នា ។ យើងមិនបាច់ចាំនិយាយប្រាប់អ្នកថា យើងបានឃើញរបស់អ្វីខ្លះនៅទីនោះទេ ត្រូវឲ្យអ្នកឯងដឹងរឿងទាំងនោះដោយខ្លួនចុះ ។ រឿងដែលយើងអាចនិយាយប្រាប់អ្នកបានយ៉ាងខ្លី គឺជារឿងនឹងហើយដែលនាំឲ្យយើងខ្វាក់ភ្នែកម្ខាងទាំង

គេសំគ្នា ។ ឯរឿងការរបស់យើងតែម្នាក់ៗ សឹងពេញទៅដោយហេតុ
គេមយ៉ាងចំឡែកអស្ចារ្យ ហើយបើចង់ការការតែរឿងទាំងនេះទុកត្រូវធ្វើ
ជាសៀវភៅ ១ យ៉ាងធំបាន ប៉ុន្តែយើងត្រូវសង្ខេបត្រឹមប៉ុណ្ណេះ មិនអាច
និយាយប្រាប់អ្នកឲ្យព្រៃទេលើសពីនេះតទៅទៀតទេ ។

អ្នកស្រី, កងចំណោមមនុស្សមជនទាំង ១០ នាក់នោះ មានម្នាក់បាន
និយាយសារសព្វប្រាប់ខ្ញុំដូច្នេះរួចហើយ ខ្ញុំក៏រុំខ្លួនចងស្បែកចៀម យក
កាំបិតវែងគេបានប្រគល់ឲ្យនោះទៅផង លុះខ្ញុំចូលទៅក្នុងស្បែកស៊ប់
ស្រួលហើយ អ្នកទាំងនោះក៏តាំងនាំគ្នាដេរ ស្រេចហើយទុកខ្ញុំចោលនៅ
ទីនោះឯង រួចនាំគ្នាថយចូលទៅក្នុងខ្ទមអស់ទៅ ។ មួយស្របក់
ស្រាប់តែសត្វស្ទ្រីហើរមកឃើញ ក៏ធ្លាក់ចុះមកសំដៅខ្ញុំ ចាប់ខ្ញុំ
នឹងក្រញាំ ក្រញុកកាន់ដោយស្មានថាជាសត្វចៀម ហើយនាំខ្ញុំទៅលើភ្នំ ១ ដ៏
ខ្ពស់ត្រដួតត្រដឹមស្មើមេឃ ។

លុះកាលដែលខ្ញុំដឹងដាក់ជាថលចុះហើយ ខ្ញុំក៏តាំងចាប់យកកាំបិត
ទៅវែស្បែកចៀមដោះខ្លួនខ្ញុំចេញមកហើយ បញ្ចាញខ្លួនទៅចំពោះមុខ
សត្វស្ទ្រីៗ គ្រាន់តែក្រឡេកឃើញខ្ញុំក៏ហើរទៅយ៉ាងរហ័ស ។ ឯសត្វ
ស្ទ្រីនោះជាសត្វស្លាបៗសម្បុរស មានខ្លួនធំហាក់ធាត់បម្បៀមណាស់ ។
ឯកំពូលភ្នំនោះខ្ពស់ក្រៃណាស់ កាលចាប់យកដំរីវាំនឹងហួរយទៅក្នុង
ពេលបាន ហើយនាំយកទៅដាក់លើកំពូលភ្នំដើម្បីជាចំណីអាហារ ។

ខ្ញុំខំទ្រាំឃ្លាតដើរសំដៅទៅរកប្រាសាទនោះ មិនឲ្យខូចពេលវេលាទេ ខ្ញុំលើកជំហានដើរវែងៗដើរទៅ ត្រឹម ១ កំណាត់ថ្ងៃក៏បានដល់ទីនោះ ខ្ញុំអាចនិយាយបានថា ប្រាសាទដែលខ្ញុំឃើញនោះ មានលំអជាងសេចក្ដីដែលគេបានពោលពណ៌នាប្រាប់ខ្ញុំនោះទៅទៀត ។ ទ្វារប្រាសាទចំហពោលគឺឥតបិទទេ ខ្ញុំក៏ដើរចូលទៅក្នុងទីលាន ១ មានសណ្ឋាន ៤ ជ្រុងហើយធំទូលាយណាស់ មានទ្វារតូចៗជុំវិញចំនួន ៩៩ ទ្វារធ្វើពីឈើខ្លឹមចន្ទន៍និងឈើកន្ទុយក្រពើ ហើយមានទ្វារ ១ នោះធ្វើពីមាស ទាំងនេះនៅមិនទាន់រាប់ទ្វារ ដែលមានជណ្ដើរជាច្រើនយ៉ាងល្អចំឡែកសម្រាប់ឡើងទៅជាន់ខ្ពស់ផងទេ ហើយនៅមានទ្វារដទៃទៀតដែលខ្ញុំមិនទាន់បានឃើញ ។ ទ្វារទាំង ១០០ នោះ សម្រាប់ជាផ្លូវចូលទៅក្នុងសួនច្បារឬ ឃ្លាំងដែលដាក់ពេញទៅដោយទ្រព្យសម្បត្តិឬមួយជាកន្លែងដែលដាក់ទុករបស់ដែលមើលឃើញចំឡែកៗទាំងអស់ ។

ខ្ញុំបានឃើញនៅចំពីមុខនោះមានទ្វារបើកចំហខ្ញុំក៏ឈានជើងដើរចូលទៅក្នុងបន្ទប់ធំ ១ នៅក្នុងនោះមានស្រីក្រមុំចំនួន ៤០ នាក់ អង្គុយនៅត្រៀបត្រាសុទ្ធតែមានរូបឆោមល្អឯកទាំងអស់ ភាពដែលខ្ញុំនឹកស្មានទៅ ដូចជាគ្មានស្រីឯណាលើសពួកនោះទៅទៀតឡើយ ។ នាងទាំងនោះសុទ្ធតែស្លៀកពាក់សំពត់យ៉ាងថ្លៃថ្នូទាំងអស់ កាលក្រឡេកមកឃើញខ្ញុំភ្លាមស្រាប់តែនាំគ្នាក្រោកស្រែកឡើងព្រមគ្នា មិនឲ្យខ្ញុំជំរាបសួរទាន់ទេ នាងទាំង

នោះនិយាយមកកាន់ខ្ញុំ ដោយសេចក្តីភ័យក្រៃពេកណាស់ថា "ម្ចាស់ថ្ងៃដ៏ក្លាហានហើយ, អ្នកអញ្ជើញមកប្រពៃហើយៗ" មានស្ត្រីម្នាក់ក្នុងចំណោមនោះ និយាយជំនួសអ្នកឯទៀតៗ ថា "អស់កាលយូរមកហើយដែលយើងនៅរង់ចាំអ្នកដ៏វិសេសម្នាក់ ដូចជារូបអ្នក ទ្រង់ទ្រាយរបស់អ្នកល្អមើលយើងស្គាល់បានថា រូបអ្នកប្រកបដោយលក្ខណៈល្អគ្រប់យ៉ាង ល្មមឲ្យយើងរង់ចាំបានទាំងអស់ យើងរាល់គ្នាមានជំនឿថាអ្នកនឹងមិនបានឃើញអ្នកណាមួយក្នុងក្រុមយើងនេះ ដែលមិនសមគួរនឹងអ្នកសោះឡើយ" ។

លុះខ្ញុំស្រឡាំងកាំងនៅយូរដូច្នោះ ទើបស្រីទាំងនោះ ចង់ឲ្យខ្ញុំអង្គុយលើកន្លែងមួយជាអាសនៈខ្ពស់បំផុត នៅពីខាងលើអាសនៈរបស់នារីទាំងនោះ ខ្ញុំបានបញ្ជាក់ថា ទីកន្លែងនោះហើយ ដែលធ្វើឲ្យខ្ញុំកើតទុក្ខក្រៀមក្រំជាទម្ងន់នៅវេលាក្រោយមក ។ ស្ត្រីទាំងនោះនិយាយមកកាន់ខ្ញុំថា "ទីនេះជាកន្លែងរបស់អ្នក តាំងពីឥឡូវនេះទៅ យើងត្រូវទុកអ្នកជាក្សត្រម្ចាស់ប្ដីនៃយើង ជាចៅហ្វាយរបស់យើង ជាចៅក្រមរបស់យើង យើងរាល់គ្នាជាទាសីរបស់អ្នក ប្រុងខ្លួនចាំទទួលសេចក្តីបង្គាប់អំពីអ្នកទាំងអស់គ្នា" ។

អូស្រី, តាមទេសភាពនេះ ខ្ញុំនឹកឆ្ងល់ចំឡែកណាស់ អំពីការធ្វើកិច្ចប្រណិប័តន៍របស់ស្ត្រីរូបស្រស់ៗអស់នោះចំពោះមកលើខ្ញុំ និយាយ

មិនបានជាមិនត្រូវ គឺនាងមួយយកទឹកក្តៅមកលាងជើងឲ្យខ្ញុំ នាងម្នាក់ទៀតយកទឹកអប់ទ្ធឹបច្ចូនមកលាក់លើដៃខ្ញុំ ពួកនាងខ្លះទៀតនាំគ្នាលើកយកអាហារភោជនយ៉ាងឆ្ងាញ់ពិសាមកឲ្យខ្ញុំ មានពួកនាងខ្លះទៀតយកកែវដាក់ស្រាយ៉ាងឆ្ងាញ់ពិសាហុចមកឲ្យខ្ញុំ ហើយស្រីទាំងអស់នោះ សុទ្ធតែមានរបៀបរបបឥតគ្គួន មានលំនាំញ៉ែងញ៉ងគួរឲ្យចាប់ចិត្តស្នេហា ៗ ឯខ្ញុំក៏តាំងផឹកទទួលបរិភោគយ៉ាងស្កប់ស្កល់ លុះរួចកិច្ចបរិភោគហើយ ពួកស្រ្តីទាំងនោះក៏នាំគ្នាបកគន្ធ័យ បោមពោមនៅជុំវិញខ្លួនខ្ញុំ សុំឲ្យខ្ញុំនិយាយអំពីរឿងធ្វើដំណើររបស់ខ្ញុំ ខ្ញុំក៏តាំងចាប់និយាយរឿងចេញទេសរបស់ខ្ញុំជាលំដាប់ហូរហែរហូតដល់ចូលយប់សន្ធ្យា ។

លុះខ្ញុំដំណាលរឿងការរបស់ខ្ញុំ ឲ្យស្រីទាំង ៤០ នាក់ស្តាប់ចប់ហើយនោះមានពួកស្រ្តីខ្លះដែលអង្គុយនៅជិតខ្ញុំ ក៏នៅតែនិយាយសន្ទនាជាមួយនឹងខ្ញុំ នៅវេលានោះ មានពួកស្រ្តីខ្លះទៀតឃើញថាយប់ហើយ ក៏នាំគ្នាក្រោកទៅយកទៀនមកអុជ ហើយបាននាំគ្នាលើកយកទៀន ១ ពុំយ៉ាងធំសំបើមអស្ចារ្យ ដែលស្រីទាំងនោះដាក់ជើងធ្វើឡើងសម្រាប់អុជបំភ្លឺឲ្យមានរបៀបរៀបរយគួរឲ្យគេសរសើរពន់ពេក ។

មានស្រ្តី ៣ ពួកទៀត នាំគ្នារៀបតុដាក់ផ្លែឈើក្រៀម, ក្រណាប់ទាំងគ្រឿងផឹកមានស្រាផ្សេងៗ យ៉ាងល្អជាច្រើនមុខ មាន ៦ ពួកទៀតរៀបគ្រឿងភ្លេងតូរ្យតន្ត្រី ។ កាលណារៀបរួចស្រេចសព្វគ្រប់ហើយ

ហើយស្ត្រីទាំងនោះអញ្ជើញខ្ញុំទៅភោជនាគារ ។ ខាងក្នុងនោះអង្គុយជាំ មួយនឹងខ្ញុំនៅតុនោះអស់មួយស្របក់ធំ ។ ហើយពួកនាងខ្លះចាប់លេងភ្លេង ហើយនៅស្រែកច្រៀងរម្យទៅជាមួយនឹងស្គរភ្លេងយ៉ាងពីរោះ ។ នាងពួក នាងខ្លះទៀតលោតរបាំទន់ជាក្បួន ៗ ក្បាច់ ម្ដង ១ ក្បួន ៗ គួរឲ្យពិតពិលរមិល. រមិលណាស់ ។

លុះរំលងពីអាធ្រាត្រទៅ នារីក្រុមក្បាច់សប្បាយទាំងឡាយក៏ផុតកម្លាំងទៅ ។ វេលានោះ មានស្ត្រីម្នាក់បាននិយាយនឹងខ្ញុំថា "អ្នកមានសេចក្ដីនឿយហត់តាមផ្លូវមកច្រើន ឥឡូវនេះ ដល់ពេលអ្នកអញ្ជើញទៅសម្រាកខ្លួនហើយ ទីបន្ទប់ដេកនៃអ្នកនេះបានរៀបចំស្រេចហើយ ប៉ុន្តែមុននឹងអ្នកចូលទៅសម្រាកក្នុងទីនោះ សូមឲ្យអ្នកជ្រើសរើសក្នុងចំណោមពួកយើងទាំងអស់នេះចុះ បើអ្នកពេញចិត្តនឹងនាងណាច្រើនជាងគេ សុំឲ្យនាំយកនាងនោះទៅសម្រាកជាមួយនឹងអ្នកផងចុះ ។ វេលានោះខ្ញុំមិនដឹងជានឹងរើសយកណាមួយណាទេ ព្រោះនាងទាំងនោះ មានរូបឆោមលោមពណ៌ល្អស្អាតប្រហែលគ្នាទាំងអស់ មានសម្ផស្សស្រស់ល្អ សុទ្ធតែសមគួរដល់ការគាប់ពេញចិត្តខ្ញុំ គួរខ្ញុំប្រណីបត្តិនឹងនារីទាំងអស់ ។

ស្ត្រីជាមេក្រុមនោះឯង បាននិយាយនឹងខ្ញុំឡើងវិញទៀតថា "យើងទាំងអស់គ្នាមានសេចក្ដីជឿជាក់ចុះចិត្ត លើសេចក្ដីទៀងត្រង់របស់អ្នក ហើយយើងយល់ឃើញថាខ្លាចក្រែងកើតមានការប្រច័ណ្ឌគ្នាក្នុងចំណោម

ពួកយើងនេះ សូមអ្នកកុំព្រួយទៀយ យើងសូមជំរាបអ្នកថា សេចក្ដីសុខ របស់ស្ត្រីណាក៏ដោយដែលអ្នកជ្រើសរើសយកទៅនោះ មិនធ្វើឲ្យយើង ច្រណែនឬប្រច័ណ្ឌគ្នាទៀយ ពីព្រោះយើងមានទឹកចិត្តដូចគ្នា ហើយ-រាល់ៗថ្ងៃ យើងគន់តែបានទទួលកិត្តិយសដូចគ្នានេះម្តងម្នាក់ៗ រហូត ដល់គំរប់៦០ថ្ងៃ ទើបចាប់ផ្ដើមសាជាថ្មីទៀតវិញ ។ សូមឲ្យអ្នកជ្រើស រើសតាមចិត្ត កុំនាំឲ្យខូចពេលវេលាសម្រាកកាយ ដែលអ្នកកំពុង ត្រូវការក្នុងវេលានេះទៀយ" ។

ទើបខ្ញុំត្រូវតែកាត់ចិត្តខ្លួនឯងសម្រេចដាច់ខាត ក្នុងខណៈនោះ ហើយខ្ញុំក៏ហុចដៃទៅឲ្យស្ត្រីដែលនិយាយជំនួសអ្នកឯទៀតៗ នោះមុនគេ នាងនោះក៏ហុចដៃនាំមកឲ្យខ្ញុំចាប់ ហើយគេនាំយើងទាំងពីរនាក់ទៅកាន់ បន្ទប់១យ៉ាងល្អពេក គេទុកឲ្យយើងនៅក្នុងបន្ទប់នោះតែពីរនាក់ រួចស្រី ឯទៀតៗ ក៏ថយទៅកាន់ទីតាំងរៀងខ្លួនទៅ ។

ដល់ព្រឹកឡើង គ្រាន់តែខ្ញុំស្លៀកពាក់រួចស្រេច ស្រីទាំង៣៩ នាក់ក៏នាំគ្នាចូលមកកាន់បន្ទប់ខ្ញុំ សុទ្ធតែពាក់តែងខ្លួនប្រាណប្លែកជាងពីថ្ងៃ មុន ។ ពួកនាងទាំងនោះក៏នាំគ្នាជំរាបសួរខ្ញុំ សួរពីសុខទុក្ខរបស់ខ្ញុំ រួចក៏នាំខ្ញុំទៅកន្លែងងូតទឹក ហើយគាំងដុសលាងខ្លួនប្រាណឲ្យខ្ញុំ ហើយ ផ្គត់ផ្គង់ប្រណិប័តន៍សព្វគ្រប់តាមដែលគេត្រូវការ រួចខ្ញុំក៏ចេញពីនោះទៅ

ហើយនាងតាំងនោះក៏នាំយកសំពត់អាវមកជាស់ឲ្យខ្ញុំ សុទ្ធសឹងល្អប្លែក ជាងពីថ្ងៃ ១ នោះទៅទៀត ។

យើងកល់គ្នា ស្ទើរតែទៅជាប់ខ្ទង់ក្រហូត ១ ថ្ងៃនោះ លុះដល់ពេលវេលាផង នាងតាំងនោះក៏និយាយសុំឲ្យជ្រើសរើសកូននាង ដើម្បីឲ្យទៅរួមដំណេកជាមួយនឹងខ្ញុំ ។ អ្នកស្រី ខ្ញុំមិនបាច់ដកប្អូនស្រីអំពីរឿងកាដដែល ៗ នោះទេ ខ្ញុំសុំដកប្អូនស្រីថា ខ្ញុំបានទៅរួមជាមួយនឹងស្រីតាំង៤០នាក់ ដោយទទួលនាងតាំងនោះម្នាក់ ៗ មករួមដំណេកជាមួយនឹងខ្ញុំ ហើយការសំកាលកំណត់នេះ ជីវិតខ្ញុំផុតជាប់ទៅដោយការគុណយ៉ាងស្កប់ស្កល់ ឥតមានផុលទោសអ្វីបន្តិចឡើយ ។

លុះរល់ទៅជាប់ឆ្នាំ (មិននាំឲ្យខ្ញុំធុញទ្រាន់) កន្លងវេលាព្រឹក ១ ស្រាប់តែស្រីតាំង ៤០ នាក់ មិនបានសំដែងសេចក្តីរីករាយស្រស់ស្រាយដូចធម្មតាបេតុផង មិនបានសួរពីសុខសប្បាយយ៉ាងណា ១ ទេ នាំគ្នាចូលមកពះទឹកឱបខ្ញុំ សុទ្ធតែមានបាលទាំងសងខាងហៀរទៅដោយទឹកភ្នែកទាំងវិញ ។ នាងតាំងនោះចូលមកឱបខ្ញុំដោយស្នេហាម្នាក់ ៗ ស្រាប់តែនិយាយប្រាប់ខ្ញុំថា "លាសិនហើយ! ក្សត្រថ្លៃសំឡាញ់ សូមក្រាបលាសិនហើយ! យើងទាំងអស់គ្នា ត្រូវចេញចាកចោលទ្រង់ឥឡូវហើយ" ។ ខ្ញុំក៏សួរទៅស្រីតាំងនោះថា "ខ្ញុំសុំទោសកាន់តាន់ព្រះនាមរបស់ព្រះ ៩ នាងល្អរបស់ខ្ញុំអើយ! សូមឲ្យនាងនិយាយប្រាប់ខ្ញុំ

ប្រសិនបើខ្ញុំអាចជួយដោះទុក្ខរបស់នាងបាន ឬមួយបើជំនួយរបស់ខ្ញុំមិនជាឥតប្រយោជន៍សម្រាប់នាងរាល់គ្នា" ។ នាងទាំងនោះមិននិយាយប្រាប់ខ្ញុំឲ្យជាក់ច្បាស់ទេ តែជានិយាយថា "យើងរាល់គ្នាលែងបានឃើញ បានស្គាល់ទ្រង់តទៅទៀតហើយ មានចំនួនអ្នកជិះសេះជាច្រើននាក់ មុនទ្រង់នេះដែលបានចូលមកចួបនឹងយើង ហើយសុទ្ធតែបានទទួលការផ្តេកផ្តិតស្នេហា អំពីយើងរាល់គ្នាដូចជាទ្រង់ដែរ ។ យើងរាល់គ្នាមិនដឹងជាធ្វើដូចម្តេច កុំឲ្យព្រាត់ប្រាសចាកទ្រង់ទៅបានឡើយ" ។ លុះនាងទាំងនោះនិយាយដូច្នេះហើយ ក៏តាំងនាំគ្នាយំខ្សឹកខ្សួលយ៉ាងអាណោចអធ័មឡើងទាំងអស់គ្នា ។

ខ្ញុំនិយាយសួរទៅទៀតថា "ម្នាលនាងសំឡាញ់ទាំងឡាយ សុំកុំយំសោកថ្វី នាងទាំងឡាយកុំធ្វើឲ្យខ្ញុំក្រៀមក្រំជាងនេះទៅទៀតឡើយ អាណិតប្រាប់ខ្ញុំអំពីហេតុនៃសេចក្តីទុក្ខរបស់នាងឲ្យខ្ញុំបានដឹងផង ។ ស្រីទាំងនោះតបមកខ្ញុំថា អនិច្ចាអើយ! នៅមានហេតុអ្វីផ្សេងទៀត ដែលអាចធ្វើឲ្យយើងមានទុក្ខព្រួយ ដែលគ្រាន់តែយើងរាល់គ្នាតោងព្រាត់ប្រាសចាកទ្រង់? ប្រហែលជាយើងលែងបានជួបនឹងទ្រង់តទៅទៀត ប្រសិនបើទ្រង់ចង់បញ្ជាក់ហេតុនោះ ប្រសិនបើហេតុនោះល្មមសមគួរដល់ទ្រង់ជួបប្រទះមែន នោះមុខជាលែងជួបប្រទះនឹងយើងរាល់គ្នា ។ ខ្ញុំឆ្លើយទៀតថា "នាងទាំងឡាយ ខ្ញុំមិនយល់សោះអំពីរឿងដែលនាង

និយាយនោះ ខ្ញុំសុំឲ្យនាងនិយាយប្រាប់ខ្ញុំឲ្យជាក់ច្បាស់ជាងនេះ ។ ទើបនាងម្នាក់និយាយឡើងថា " ប្រពៃហើយទ្រង់, ដើម្បីធ្វើឲ្យទ្រង់សព្វព្រះទ័យ យើងកល់គ្នាសូមក្រាបទូលទ្រង់ថា យើងទាំងអស់គ្នា សុទ្ធតែជាក្សត្រីជាបុត្រីរបស់ស្តេចជាច្រើនអង្គ ។ យើងនៅក្នុងវាំងនេះជាមួយគ្នាដោយស្ម័គ្រចិត្ត ដូចទ្រង់បានទតឃើញហើយ ប៉ុន្តែលុះដល់ចុងឆ្នាំនិមួយ ៗ យើងត្រូវតែចេញបាត់ទៅពីវាំងនេះក្នុងកំណត់ ៤០ ថ្ងៃ ដើម្បីធ្វើការសំខាន់ខានពុំបានឡើយ ដែលជាការមិនបើកឲ្យយើងនិយាយការសម្ងាត់នេះទេ លុះរួចកិច្ចនោះហើយ ទើបយើងត្រឡប់មកក្នុងប្រាសាទនេះវិញបានកល់គ្នា ។ ឥឡូវដាច់ឆ្នាំពីម្សិលមិញនេះហើយ ត្រូវតែយើងចេញចោលទ្រង់ទៅឥឡូវនេះឯង គឺរឿងនេះហើយដែលយើងកល់គ្នាមានសេចក្តីក្រៀមក្រំ ។ មុនយើងចេញទៅ យើងទុកកូនសោរបស់ទ្រព្យទាំងអស់ជូនទ្រង់ ដូចជាសោទ្វារទាំង ១០០ ទ្វារហើយនៅក្នុងនោះ ទ្រង់នឹងបានឃើញអ្វី ៗ ជាទីនាប់ចិត្តនិងជាទីកំសាន្តចិត្តកែអផ្សុកក្នុងកាលដែលយើងកល់គ្នាមិននៅ ។ ប៉ុន្តែដើម្បីសេចក្តីសុខសប្បាយរបស់ទ្រង់ និងដើម្បីជាប្រយោជន៍ដល់យើងកល់គ្នាដោយឡែកផង យើងសូមផ្តាំទ្រង់ថា កុំបីតាក់សាបើកទ្វារមាសឡើយ ។ ប្រសិនបើទ្រង់បើក មុខជាយើងកល់គ្នាខានបានជួបនឹងទ្រង់តទៅទៀត ហើយជាការនាំឲ្យយើងមានទុក្ខព្រួយកាន់តែច្រើនឡើងទៀត ។ យើងមានសង្ឃឹមថា

ទ្រង់មុខជាធ្វើតាមបណ្តាំ ដែលយើងកល់គ្នាបានក្រាបទូលមកនេះ ។ ដើម្បីឲ្យទ្រង់សម្រាកព្រះអង្គបានស្រួល និងសុខសម្រាន្តក្នុងព្រះវរកាយ សូមទ្រង់ប្រយ័ត្នកុំបីធ្វេសឡើយ ។ ប្រសិនបើទ្រង់នៅតែបេះបង់ ទ្រង់ជាបឲ្យក្រលែងទៅទៀត មុខជាទ្រង់មានកំហុសធំមិនខាន យើងកល់គ្នាសូមអង្វរទ្រង់ កុំបីធ្វើឲ្យមានកំហុសនេះឡើយ ហើយឲ្យយើងកល់គ្នាបានជួបប្រទះនឹងទ្រង់ទៀត នៅទីនេះក្នុងកំណត់ ៤០ ថ្ងៃ ។ បើយើងនឹងយកសោភាមោសជាប់ទៅជាមួយនឹងយើងទៅ ការធ្វើដូច្នេះជាការមើលងាយប្រមាថដល់ក្សត្រដូចជាទ្រង់ ហាក់ដូចជាមិនទុកចិត្តនឹងការស្ងប់ស្ងៀមនឹងធឹងរបស់ទ្រង់សោះឡើយ ។

ពាក្យសំដីរបស់ក្សត្រីរូបស្រស់ស្រស់នោះ នាំឲ្យខ្ញុំមានសេចក្តីព្រួយចិត្តជាខ្លាំង ។ ខ្ញុំក៏បានសំដែងនូវកកិត្តឲ្យឃើញថា នៅវេលាដែលកល់គ្នាមិននៅនេះ ខ្ញុំមានសេចក្តីក្រៀមក្រំចិត្តជាច្រើន ហើយសូមអរគុណដល់បណ្តាំរបស់នាងទាំងនោះ ដែលបានផ្តាំផ្ញើដោយមេត្រីចិត្ត ខ្ញុំក៏ថ្លែងថា ខ្ញុំតាំងចិត្តនឹងធ្វើខ្លួនខ្ញុំឲ្យបានសុខសប្បាយតាមទំនងដែលអាចរកមកបានដោយខ្លួនឯង ក្នុងរវាងនៃថ្ងៃដែលយើងត្រូវតែព្រាត់ប្រាសគ្នា នៅទីបំផុត ខ្ញុំបានឱបថើបក្សត្រីទាំងនោះម្តងម្នាក់ៗ គ្រប់ៗគ្នា រួចនាងទាំងនោះក៏នាំគ្នាចេញទៅ នៅតែខ្ញុំម្នាក់ឯងនៅក្នុងប្រាសាទដ៏រហោស្ថាននោះ ។

សេចក្ដីសាមគ្គីចង់ភ្ជាប់គ្នា សេចក្ដីស្នេហាដ៏ស្មោះស្ម័គ្រ សេចក្ដីស្រុះស្រួលមូលចិត្តគំនិតគ្នា សេចក្ដីក្សេមក្សាន្តរីករាយ នោះខ្ញុំបានទទួលសេពសោយហូត ១ ឆ្នាំ ខ្ញុំមិនដែលមានសេចក្ដីថ្នាំងថ្នាក់អាក់អន់ចិត្តបន្តិចឡើយ នៅក្នុងប្រាសាទដ៏សុខសម្រាន្តនោះ ។ ខ្ញុំមិនដែលបានយកភ្នែកក្រឡេកគយគន់មើលតែនាងឡាយសឹងល្អ ១ ចំឡែកកប់ដោយពានមុខ ឲ្យក្រៃលែងជាងលំអោមរើតរបស់ស្ដ្រីទាំងនោះ ទីងការសប្បាយចិត្តដែលបានមើលស្ដ្រីទាំងនោះ យកចិត្តទុកដាក់នឹងខ្ញុំតែម្នាក់ប៉ុណ្ណោះ ខ្ញុំមានចិត្តក្រៀមក្រំសោកស្ដាយ ដែលស្ដ្រីទាំងនោះកោងចេញពេលខ្ញុំទៅ ហើយក្នុងកំណត់ ៤០ ថ្ងៃដែលស្ដ្រីទាំងនោះមិននៅ ក៏ប្រាកដដល់ចិត្តគំនិតរបស់ខ្ញុំ ហាក់ដូចជាយូរណាស់ដល់ ១០០ ឆ្នាំតែម្ដង ។

ខ្ញុំមិនភ្លេចពាក្យបណ្ដាំដ៏សំខាន់ ដែលស្ដ្រីទាំងនោះបាននិយាយនឹងខ្ញុំ គឺហាមប្រាមយ៉ាងដាច់ខាត កុំឲ្យខ្ញុំបើកទ្វារមាស ។ ទើបខ្ញុំយកកូនសោរបស់ទ្វារទាំង ១០០ ដែលគេដាក់រៀបរៀងមានរបៀបរៀបរយល្អ ទើបខ្ញុំយកកូនសោទី ១ ទៅបើកទ្វារដំបូង ហើយខ្ញុំដើរចូលទៅក្នុងសួនច្បារនោះ ។ ក្នុងសួននេះមានសុទ្ធតែឈើផ្លែ សឹងមានផ្លែដេរដាសស្មេតស្មះព្រេនជាអនេក ខ្ញុំស្មានថា ក្នុងពិភពលោកនេះមិនមានកន្លែងណាយកមកប្រៀបផ្ទឹមបានឡើយ ។ សូម្បីក្នុងសាសនា

យើងដែលបាននិយាយដំណាលពីសួនស្ថានសួគ៌ ថាប្រកបដោយ
ឈើផ្លែល្អស្គារយ៉ាងណា គង់តែមិនវិសេសជាងទីនុះឡើយ ។
ឈើផ្លែទាំងនោះ ប្រកបដោយដើមក្រង់លេញមានរបៀបរៀបរយល្អ
មានទំហំដើមប៉ុន ៗ គ្នា នាងកំពស់ស្មើគ្នាមានផ្លែផ្សេង ៗ ច្រើនជាតនេក
ណាស់ តាំងពីកើតមកខ្ញុំមិនដែលប្រទះឃើញឈើផ្លែមានសភាពដូច្នេះ
ឡើយ កាលបើពាលភ្នែកក្រឡេកមើលទៅ គួរឲ្យត្រជាក់ភ្នែកកើត
ចិត្តរីករាយជាចំឡែកណាស់ ។ អ្នកស្រី, ខ្ញុំសូមជំរាបថា នៅទីសួន
នោះ មានព្រែកជីកខ្វាត់ខ្វែង មានរបៀបរៀបរយទាំងអស់ នាំបង្អើក
ការផ្លាស់ទឹកមានចំនួនគ្រប់គ្រាន់ ល្មមឲ្យដើមឈើទាំងនោះ ស្រូបពញ្ញក់
យកជាតិទឹកថ្នាល្អយកទៅជប់លៀងដើមនិងឫស នាំបង្កើតជាផ្លែផ្កា
យ៉ាងស្កុកស្កម្ភតាមរដូវកាល ឯចំនួនផ្លែក្នុង ១ ដើម ៗ នោះមានច្រើន
ណាស់ មើលឃើញទុំក្រហមច្រាលជាទិច្ច ស្ទើរតែរកស្លឹកគ្មាន ហើយ
សុទ្ធតែផ្លែស ៗ ល្អទាំងអស់ ។ អ្នកស្រី, ខ្ញុំគាំងដើរតែយកនំទៀន
នោះមិនបេះផ្លែគង្គស្រោះ ក្រែងម្ចាយក្រែងទកមិនដឹកឃ្លានឡើយ បើកុំតែ
ខ្ញុំជាអ្នកមានគំនិតគិតគូរស្រេចជាមុន កុំអីខ្ញុំចេញពាក្យនោះពុំរួចឡើយ
លុះខ្ញុំត្រឡប់ចេញមកហើយក៏បិទទ្វារចាក់សោទៅវិញ ទើបខ្ញុំចាក់
សោបើកទ្វារមួយទៀតទៅទៀត ។ (មានត)

មិត្រសំឡាញ់ទុច្ចរិតគ្នា

មានបុរសពីរនាក់ឈ្មោះគោត ១ ឈ្មោះផៃ ១ ជាមិត្តភក្តិបាន គ្នាទៅវិញទៅមក ។ គួនថ្ងៃមួយ ផៃខ្វះប្រាក់ចាយក៏ទៅនិយាយសូមខ្ចី ប្រាក់គោតចំនួន ៥០០០០ សិន; គោតក៏ព្រមឲ្យភ្លាមៗ ប៉ុន្តែនិយាយ សូមឲ្យផៃធ្វើសំបុត្រចុះហត្ថលេខាជាគ្រឿងសំគាល់ទុកលើផៃខ្លួន ទើប ប្រគល់ប្រាក់ឲ្យ ។ ផៃក៏យល់ព្រមតាមរួចហើយត្រឡប់ទៅផ្ទះវិញ, ធ្វើ សំបុត្រចុះហត្ថលេខាតែម្នាក់ឯង ហើយយកមកឲ្យគោត។ បានទទួលសំ- បុត្រមើលឃើញសេចក្តីសព្វគ្រប់ហើយក៏សួរទៅសំឡាញ់ថា “ហេតុដូច ម្តេចក៏មិនឲ្យអ្នកស្រីជាភរិយាចុះហត្ថលេខាជាមួយផង? ការនេះមិនមែន ជាធុនស្រាលអ្វីប៉ុន្មានទេ ព្រោះយើងទាំងពីរនាក់ជាមិត្តសំឡាញ់នឹងគ្នា ពួនកាលសំឡាញ់ទាល់ ពួនកាលខ្ញុំទាល់ តែងតែពឹងពាក់គ្នាទៅវិញទៅ មក, បើគ្រាន់តែធ្វើសំបុត្រចុះហត្ថលេខាជាក់ស្តែង ក្រែងលោពួនជា អ្នកមួយក្ស័យ អ្នកមួយរលីងហើយទំងបានសងគ្នាដោយស្រួលប៉ុណ្ណោះទេ តើ ខ្ញុំមិនមែនតឹងរ៉ឹងដោយមិនចង់ឲ្យសំឡាញ់ខ្ចីនោះទេ ដូចយើងស្គាល់ គ្នាស្និទ្ធនឹងគ្នាស្រាប់ហើយ” ។ ផៃបានស្តាប់ហើយក៏លាសំឡាញ់ប្រញាប់ ប្រញាល់ត្រឡប់ទៅផ្ទះវិញ, ឲ្យប្រពន្ធចុះហត្ថលេខាក្នុងសំបុត្រសន្យា នោះថែមទៀតរួចហើយយកមកឲ្យសំឡាញ់វិញ: គោតបានទទួលសំបុត្រ ហើយសំឡឹងមើលមួយស្របក់ក៏និយាយថា “សំឡាញ់ធ្វើសំបុត្រនេះ

ត្រឹមត្រូវល្អពិតប្រាកដមែនហើយ ប៉ុន្តែនៅខ្វះបន្តិចទៀតមិនទាន់ពេញចិត្តខ្ញុំនៅឡើយ" ។

ដៃ – នៅខ្វះដូចម្តេចទៀត, សំឡាញ់ពេញចិត្តយ៉ាងណាវិញ ?

គោត – ចិត្តខ្ញុំចង់ឲ្យសំឡាញ់ទិញក្រដាសមួយពុម្ពធំហើយជួលជាងណាដែលដៃចំណាន ខាងគូរយ៉ាងចំណាប់មកឲ្យគូររូបឲ្យស្អាតបាតល្អ ។

ដៃ – ចុះហេតុអ្វីក៏ចាំបាច់ឲ្យជាងគូររូបនោះ, ហើយគូររូបអ្វី ?

គោត – គូររូបយើងទាំងពីរនាក់ ព្រោះខ្ញុំយល់ឃើញយ៉ាងនេះគឺ កាលជាន់មុនៗ មានគេមកសូមខ្ចីប្រាក់ខ្ញុំហើយមានទាំងធ្វើសំបុត្រចុះហត្ថលេខាកំណត់ថ្ងៃខែឆ្នាំនឹងចំនួនទឹកប្រាក់ ដូចជាសម្មាញ់ដូច្នេះដែរ ប៉ុន្តែលុះដល់កំណត់ដែលនឹងត្រូវសងវិញនោះ បើទនែកើតហេតុតាស់ចិត្តអាក់អន់មិនស្រុះស្រួលនឹងគ្នាសោះ សូម្បីតែបានប្រាក់យកមកសងវិញហើយ ក៏សំដែងអាការទឹកមុខមិនស្រស់បស់ដូចជាកាលដែលខ្ចីមកសូមខ្ចីនោះឡើយ ដោយហេតុនេះទើបខ្ញុំគិតតែរឿងនេះជាថ្មី ចង់ឲ្យសំឡាញ់រកក្រដាសមួយពុម្ពយ៉ាងធំ ហើយជួលជាងឲ្យគូររូបយើងទុកជាគ្រឿងសំគាល់នៅថ្ងៃក្រោយ គឺមុនដំបូងគូររូបសំឡាញ់ដែលមកផ្ទះខ្ញុំក្នុងថ្ងៃនេះ ហើយធ្វើទឹកមុខញញឹមញញែមរាក់ទាក់និយាយសូមខ្ចីប្រាក់ខ្ញុំ ទីពីរគូររូបខ្ញុំដែលយល់ព្រមឲ្យប្រាក់ទៅសំឡាញ់ដោយសេចក្តីរាក់ទាក់ដែរ ហើយគូររូបយើងទាំងពីរនាក់ទៀតក្នុងពេលដែលគ្រប់កំណត់ថ្ងៃ-ខែ-ឆ្នាំដែលខ្ញុំ

មិនត្រូវទារប្រាក់វិញនោះ គឺខ្ញុំទារដោយធ្វើកម្មខញ្ញ ញើមបាំងសំឡាញ់ ដែលយកប្រាក់មកសងខ្ញុំនោះក៏សំដែងអាការក្រោយ ដូចជាកាលដែល មកសូមខ្ចីដូច្នោះដែរ កុំឲ្យធ្វើមុខជូរក្រញូវដូចជាមុខមនុស្សកំពុងប្រែន ល្អាក់ថាផ្ទាចង់ឈាមកនោះឡើយ ។

## រៀបរាប់សេចក្ដីជាគតិយ៉ាងនេះ

ជាតិមនុស្សក្នុងលោក ច្រើនតែដូចគ្នា គាត់ថាមែនហើយ កាលខ្លួនខ្វះប្រាក់ លុយកាក់អ្នកអើយ មកខ្ចីគេហើយ ធ្វើមុខកែកាយ ។ ពោលពាក្យពីរោះ អន្លង់ស្មោះស្មោះ ឲ្យគេសប្បាយ លុះគេឲ្យមក ខ្លួនបានទៅចាយ ចិញ្ចឹមរូបកាយ ឬកូនប្រពន្ធ ។ រួចហើយបំភ្លេច ចួនកាលប្រះគេច ហាក់មិនគិតគន់ ដល់គេរំលឹក ខ្លួនទឹកមុខប្រែ ធ្វើមុខជូរស្អុន ចូលជាន់ថ្ងៃ ១ ៗ ពាល់តែឮសប្រាក់ ក្ដៅចិត្តថាំងថាក់ ក្រហាក់ជេរស្តី ផង់ដែកគក់ ឈ្មោះភ្នាក់គក្ដី មួយទៅជាបី អប្រិយកេរ្តិ៍ឈ្មោះ ។ ហេតុនេះអ្នកអើយ បើខ្ចីគេហើយ ត្រូវសងដោយស្មោះ កុំឲ្យគេទារ ហាំឲ្យវៃមោះ ថ្ងៃនាំកើតឈ្លោះ ពីព្រោះតែខ្លួន ។ កុំបាច់ឲ្យគេតែតិតតរះ គួររួបរាំមួន ជាក់ក្ដីទំណាក់ សងគប្រមួន គួរយាំងដូចខ្លួន គោរពនោះឡើយ ។

វិជ្ជាពិជគាថា

# ឃុនសុវត្ថិពេទ្យ ឃ្លូរ-អ៊ុន រៀបរៀង

(តមក)

ម្យ៉ាងទៀតពួកអសប្បុរសតែងពោលពាក្យជាទំនាស់នឹងពុទ្ធសាសនា ដូចពុទ្ធសាសនាថា " សត្វទាំងឡាយកាលស្លាប់ទៅហើយតែងកើតទៀត លើកតែព្រះអរហន្តចេញ " ពាក្យអសប្បុរសថា សត្វស្លាប់កើតទៀតមែន តែកុំចូលចិត្តថា រូបខ្មោចនោះកើតទៀត អ្នកក្រៅពីខ្មោចនោះទើបធ្វើសត្វឲ្យកើតឡើងបាន, ឧទាហរណ៍ដូចប្តីស្លាប់ទៅជាខ្មោចៗ នេះក៏អស់មានកំណើតត្រឹមប៉ុណ្ណេះ, ចំណែកប្រពន្ធ ឬ កូនប្រុសស្រីដែលរស់នៅ កាលបើមានគូស្រករក្នុងវេលាណា រមែងមានកូនតូចជាចៅចាប់តរៀងទៅ, នេះឯងហៅថា ស្លាប់កើតទៀត, ប្រៀបដូចដើមចេកដែលគេកាត់ផ្តាច់ពីគល់ចេញហើយ ដើមនោះក៏ត្រូវតែពុករលួយទៅ, ចំណែកគល់ដែលគេកាត់ផ្តាច់នៅក្នុងផែនដីវិញឲ្យកូនដុះដុះចេញមកបាន ។ មួយទៀត ពុទ្ធសាសនាថា "ធ្វើបុណ្យបានបុណ្យ ធ្វើបាបបានបាប" ពាក្យអសប្បុរសថា ពាក្យនោះត្រូវមែន, តែផលបុណ្យផលបាបនោះមិនមែនយើងត្រូវចាំទទួលយកក្នុងលោកឯណាទេ គឺឲ្យផលតែក្នុងពេលដែលយើងកំពុងនៅរស់ បើស្លាប់ទៅហើយក៏ហើយគ្នា, ក្នុងយ៉ាងដូចមនុស្សធ្វើចោរកម្ម, ផលកំពើនេះជាត្រូវទៅសោយទុក្ខក្នុង នរក, ប្រេត, តិរច្ឆាន,

អសុរកាយ, អបាយភូមិទាំង ៤ នេះ មិនមែននៅក្នុងលោកឯណាទេ គឺនៅតែក្នុងលោកនេះ, ចុះនរកគឺអ្វី គឺគុក, ប្រេតគឺអ្វី គឺអ្នកទោស, តិរច្ឆានគឺអ្វី គឺអ្នកទោសដែលជាប់ការប្រើឲ្យធ្វើការមិនគិតថ្លៃឈ្នួលដូចប្រើសត្វតិរច្ឆាន, អសុរកាយគឺអ្វី គឺអ្នកទោសដែលជាប់គុកហើយបង្ខំខ្លួនទៅមិនឲ្យមានទីបានជួបប្រះឃើញមុខឡើយ ក្រៅតែឲ្យឃើញ:ទើបឃើញក្ដុន” ពាក្យយ៉ាងនេះជាដើមឈ្មោះថា អសទ្ធម្មកថា, មិនតែប៉ុណ្ណោះ សូម្បីពាក្យដែលគេជេរប្រទេច ពាក្យបញ្ចុះឲ្យល្មួចល្មួង ឲ្យកាប់ចាក់ជាដើម ដែលជាពាក្យនាំឲ្យធ្លង់សេចក្តីក្រោធ ឬឲ្យធ្លង់សេចក្តីអាក្រក់ដល់អ្នកស្តាប់ នេះក៏ហៅថា អសទ្ធម្មកថា ដែរ ។ បុគ្គលឯណាបានស្តាប់អសទ្ធម្មកថាបែបនេះ ហើយជឿកាន់យកជាប្រមាណក្នុងពេលណា ក្នុងពេលនោះ បណ្ឌិតតែងប្រាប់ថា មិច្ឆាទិដ្ឋិកើតឡើងដល់បុគ្គលនោះ ។

២ — <u>មិនធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញា</u> នេះបានដល់ការប្រើគំនិតដែលមានសទ្ធានិងបញ្ញាមិនស្មើគ្នា, ដូចជានឹមនោះមានកំលាំងមិនស្មើគ្នា មែនពិត ធម្មតាគំនិតរបស់មនុស្សយើងដែលគិតការអ្វីមួយហើយ កាលបើធម៌ ២ ប្រការ គឺសទ្ធានិងបញ្ញាមិនមានកំលាំងស្មើគ្នាទេ គំនិតនោះឯងក៏ប្រែងក្លាយទៅជាមិច្ឆាទិដ្ឋិ ។

ចុះមនុស្សពួកណា ដែលប្រើកំលាំងសទ្ធាច្រើនជាងបញ្ញា ?

មនុស្សទន់អន់ប្រាជ្ញ ប្រើកំលាំងសទ្ធាច្រើនជាងបញ្ញា គឺកាលបើឮគេនិយាយអ្វី ក៏ជឿចូលចិត្តកាន់តាមយ៉ាងងាយ ៗ ឥតមានគិតពីខុសត្រូវ ឬសមហេតុសមផលឡើយ, បើគិតពិនិត្យការអ្វីមួយ ដែលជាហេតុហួសកំលាំងប្រាជ្ញាខ្លួន ក៏មិនរកសួរគេទេ ស្រាប់តែប្រកាន់ជឿតាមយោបល់ខ្លួនតែម្តង គួរហោងដូចមនុស្សពួក ១ រៀនកម្មដ្ឋានមានវិធីតាំងគូផ្សំព្យញ្ជនៈ ៣៣ តួ គឺព្យញ្ជនៈតាំងពី ក ដល់ អ ផ្សំកើតបានជាលេខ ៣២ គ្រប់ ៗ តួ ហើយចុះសន្និដ្ឋានថា ព្យញ្ជនៈ ៣២ តួនេះ អាចបង្កើតបានជាអាការរបស់មនុស្ស ៣២ ដូចពាក្យថា " ក កើតជាកេសា សក់សោកណា ៩ លាន ខ កើតជាលោមខាន កប់ទៅបាន ៩ កោដិ" ដូច្នេះជាដើម, ចំណែកឯព្យញ្ជនៈទី ៣៣ គឺ អំ (o) ថាអាចបង្កើតបានជាវិញ្ញាណរបស់មនុស្ស ។ ក៏សេចក្តីយល់ឃើញបែបនេះ មិនត្រូវសោះ ព្រោះអក្សរមិនមែនធ្វើមនុស្សឲ្យកើតទេ, មនុស្សយើងតើបង្កើតអក្សរឡើង សម្រាប់ប្រើដាក់ពាក្យតាមភាសារបស់ជាតិនិមួយ ៗ ព្រោះហេតុនោះ ទើបអក្សរគ្រប់ភាសាក្នុងលោកមិនត្រូវគ្នាដោយសណ្ឋានខ្លះ មិនត្រូវគ្នាដោយសំនៀងដែលអានខ្លះ, មិនត្រូវគ្នាដោយចំនួនខ្លះ ដូចអក្សរសម្រាប់ភាសាខ្មែរមាន ៥៤ តួ ដែលជាស្រៈ ២១ តួ ជាព្យញ្ជនៈ ៣៣ តួ, អក្សរសម្រាប់ភាសាបារាំងមាន ២៦ តួ

បែកជាស្រៈ ៦ តួ ជាព្យញ្ជនៈ ២០ តួ; បើចូលចិត្តថា អក្សរខ្មែរដែលជាព្យញ្ជនៈ ៣៣ តួ គាប់បង្កើតបានជាផ្លូវប្លោះៗ ចុះអក្សរបារាំងដែលជាព្យញ្ជនៈមានតែ ២០ តួ កាលបើយ៉ាងនេះ តើភាសារបស់ជាតិបារាំងមានខ្វះពីខ្មែរត្រង់ណាខ្លះ? ធៀបមើលតែប៉ុណ្ណោះ ក៏ឃើញថា ការយល់ឃើញរបស់មនុស្សពួកនោះមិនត្រូវ ទើបហៅថា មិច្ឆាទិដ្ឋិ ។

ចុះមនុស្សពួកណា ប្រើកម្លាំងបញ្ញាប្រែនជាធំសង្ខា?

មនុស្សបានត្រាញ់ ប្រើកម្លាំងបញ្ញាប្រែនជាធំសង្ខា, គឺជាអ្នកមិនសូវជឿពាក្យគេក្លាយៗទេ, បើគិតគ្រប់ប្រែនមិនយកតាមពាក្យគេមកតាមគំនិតគេឡើយ, សូម្បីវិជ្ជាដែលខ្លួនរៀនបានដឹងមកខ្លះៗ ក៏មិនយកមកធ្វើជាប្រមាណនៃផ្លូវគំនិត ស៊ូជឿកាន់តែតាមយោបល់ឃើញយល់របស់ខ្លួនវិញ មនុស្សបែបនេះ, ប្រើនប្រើគំនិតលង់ផុត ដែលត្រូវនិទេសថាជាមិច្ឆាទិដ្ឋិ, ត្បិតយ៉ាងដូចមនុស្ស ១ ពួក គិតឃើញថា " ឋានសួគ៌មិនមាន, ទេវតាមិនមាន " មនុស្ស ១ ពួកទៀតថា " ឋានសួគ៌មាន ទេវតាក៏មានដែរ " តែមិនមែននៅឯណាទេ, គឺនៅតែក្នុងមនុស្សលោកនេះឯង. ចុះទីណាដែលគេថាជាឋានសួគ៌? ទីក្រុងធំៗ ក្នុងនគរអ្វីៗ ក្នុងប្រទេសមួយៗ ឈ្មោះថាឋានសួគ៌ ព្រោះពាក្យថា សួគ៌ៗ ប្រែថា " ទីពេញសម្បូណ៌ដោយអារម្មណ៍ដ៏ប្រសើរលើសទីឯទៀតៗ " ។ ចុះអ្នកណាដែលគេថាជាទេវតា? មនុស្សដែលសម្បូណ៌ដោយកាម

គុណ ៥ ហៅថា ទេវតា ព្រោះពាក្យថា ទេវតាៗ នែថា "អ្នកលេងកាមគុណ" ៗ ក៏មនុស្សណាយល់ឃើញបែបនេះ បណ្ឌិតគប្បីជ្រាបថា មនុស្សនោះឯង ច្រើនប្រកាន់យកត្រង់ឃើញនឹងភ្នែកជាប្រមាណ, ហេតុនោះបានជាយល់ថា ឋានសួគ៌មិនមាន ឬថាមានដែរតែមិនមែននៅក្នុងទេវលោក ៗ បើប្រកាន់យកតែឃើញនឹងភ្នែក ទើបថារបស់នោះៗ មានដូច្នោះ ចុះមនុស្សយើងក្នុងលោកនេះ មានច្រើនជាតិច្រើនសាសន៍ណាស់ អ្នកនោះឯងគង់មិនទាន់ឃើញមិនទាន់ស្គាល់សព្វគ្រប់ដែរ, កាលបើយ៉ាងនេះ មានតែជាតិណាសាសន៍ណាដែលអ្នកនោះមិនទាន់ឃើញ, ជាតិនោះសាសន៍នោះនឹងមិនមានក្នុងលោកនេះឬ? ដូចយ៉ាងជាតិមនុស្សក្នុងនានាប្រទេសណាមួយ កាលដែលគេមិនទាន់ចូលមកក្នុងស្រុកយើង ៗ គ្រាន់តែឮគេថា, ប្រហែលមនុស្សដែលយល់ឃើញថា "ឋានសួគ៌មិនមានឬថាមានដែរ តែមិនមែននៅឯទេវលោក" មុខជាមិនជឿពាក្យដែលគេថានោះ, បើមិនជឿថាមានជាតិមនុស្សទាំងនោះទេ គេនឹងឲ្យឈ្មោះអ្នកនោះថាដូចម្ដេច? បៀបមើលតែប៉ុណ្ណោះ ក៏គង់ឃើញថា មនុស្សដែលប្រកាន់ថា "ឋានសួគ៌មិនមាន ឬ មានដែរតែនៅក្នុងមនុស្សលោកនេះ" នោះជាតិមិច្ឆាទិដ្ឋិ ៗ នេះសំដែងដោយយកហារទេសនា, ចំណែកក្នុងគម្ពីរបដុក្កកថា អយោនិសោមនសិការ: គឺការមិនធ្វើទុក

ក្នុងចិត្តដោយមុខប្រាជ្ញានោះ មាន ៤ យ៉ាង, ក្នុងទីនេះ ខ្ញុំគ្រាន់តែលើកមកឲ្យឃើញ ដើម្បីជាគ្រឿងប្រដាប់ប្រាជ្ញានៃអ្នកសិក្សាបានខ្លះគឺ

១ - អនិច្ចេ និច្ចទិដ្ឋិ យល់ថាទៀងក្នុងចំណែកដែលមិនទៀង

២ - ទុក្ខេ សុខទិដ្ឋិ យល់ថាសុខក្នុងចំណែកជាទុក្ខ

៣ - អនត្តនិ អត្តទិដ្ឋិ យល់ថាខ្លួនក្នុងចំណែកដែលមិនមែនខ្លួន

៤ - អសុភេ សុភទិដ្ឋិ យល់ថាល្អក្នុងចំណែកដែលមិនល្អ ។

មិច្ឆាទិដ្ឋិ កាលបើកើតមានឡើងតែងកើតដោយហេតុ ២ ប្រការនោះ ហេតុណាមួយ ដូចអធិប្បាយមកនេះឯង ។ សាធុជនកាលទំពិនិត្យត្រូវមើលគំនិតរបស់ខ្លួនឲ្យដឹងថា គំនិតអាត្មាអញធ្លាក់ក្នុងធម៌នោះហើយឬនៅឡើយទេ នោះត្រូវបង្កើតដោយ

## អង្គមិច្ឆាទិដ្ឋិ ២ ប្រការ គឺ

១ - វត្ថុនោ តថាតា ការវិបរិតតា វត្ថុដែលពិតជាទំនាស់និងអាការដែលខ្លួនជឿកាន់

២ - យថា ច តំ គណ្ហាតិ តថាភាវេន អសម្បដ្ឋានំ ខ្លួនជឿកាន់នូវវត្ថុនោះថាយ៉ាងណា វត្ថុនោះក៏មិនប្រាកដយ៉ាងនោះ ។

បណ្ដាអង្គទាំង ២ ប្រការនេះ អង្គទី ១ ជាអង្គខាងក្រៅ បានដល់វត្ថុទាំងពួងក្នុងលោកដែលជារបស់ពិត គឺបើមិនទៀងក៏មិនទៀងពិត, ដែល

ផលទុក្ខក៏ជាទុក្ខពិត, ដែលមិនមែនខ្លួនក៏មិនមែនខ្លួនពិត, ដែលមិនល្អក៏មិនល្អពិតជាដើម ។ អត្ថទី ២ ជាអត្ថខាងក្នុង បានដល់គំនិតដែលប្រកាន់ចំពោះវត្ថុដែលពិតនោះថាមិនពិតវិញ គឺគំនិតដែលយល់ឃើញខុសថាជាត្រូវ, ត្រូវថាជាខុស ។ សាធុជនកាលបើពិនិត្យទៅឃើញព្រមដោយអត្ថ ២ ប្រការនេះហើយ ត្រូវជ្រាបចុះថា ការយល់នោះជាមិច្ឆាទិដ្ឋិ ។ កាលបើមិច្ឆាទិដ្ឋិ គឺការយល់ខុសមានក្នុងសន្តានហើយការត្រិះរិះខុស, ការពោលពាក្យខុស, ការធ្វើខុស, ការចិញ្ចឹមជីវិតខុស, ព្យាយាមខុស, ការដំកល់ស្មារតីខុស, ការស៊ប់ស្មាធិខុស ក៏កើតមានឡើងជាលំដាប់គ្នា ព្រោះបណ្ដាមិច្ឆត្តធម៌គឺធម៌មានសភាពខុសទាំង ៨, មិច្ឆាទិដ្ឋិនេះឯង ជាធម៌នាំមកឲ្យមិច្ឆត្តធម៌ទាំង ៧ កើតឡើងបាន ។

## មិច្ឆាទិដ្ឋិ ក្លាយជា សម្មាទិដ្ឋិ

មិច្ឆាទិដ្ឋិនឹងក្លាយទៅជាសម្មាទិដ្ឋិវិញបានឬទេ? បើប្រែក្លាយបាន តើប្រែប្រួលដោយហេតុប៉ុន្មានយ៉ាង? គឺអ្វីខ្លះ? ចូរអធិប្បាយមកមើល ។

ប្រែក្លាយបាន, ប្រកបដោយហេតុ ២ យ៉ាងគឺ

១- បរតោ ឃោសោ ឧស្សាហ៍ស្ដាប់សំឡេងពាក្យពីបុគ្គលដទៃ

២- យោនិសោ មនសិការោ ធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញា ។

ហេតុទាំង ២ ប្រការនេះ មានសេចក្ដីអធិប្បាយផ្សំគ្នានឹងហេតុ

កើតមិច្ឆាទិដ្ឋិជួបអធិប្បាយខ្លះមកហើយ; តែបើទុកជាដូច្នោះ ខ្ញុំនឹងអធិប្បាយគន្លងទីនេះ មិនឲ្យដូចសាំងដែលលើសេចក្ដីមុនទេ ដើម្បីជាគ្រឿងប្រដាប់បញ្ញានៃអ្នកបានមើល ឬ បានស្ដាប់ ដូចតទៅនេះ ៗ

១. ឧស្សាហ៍ស្ដាប់សទ្ធម្មកថាអំពីបុគ្គលដទៃ, ពាក្យថា សទ្ធម្មកថា ប្រែថា "កថាជាសទ្ធម្មគឺពាក្យជាធម៌របស់សប្បុរស" ពាក្យថា បុគ្គលដទៃ សំដៅយកសប្បុរសៗ ប្រែថា "បុរសអ្នកស្ងប់រម្ងាប់" បានដល់អ្នកប្រាជ្ញមានគត់ កាយ វាចា ចិត្ត ឲ្យស្ងប់ស្ងាត់ចាកបាបធម៌ ព្រមទាំងប្រកបដោយសប្បុរសធម៌ ៧ យ៉ាងក្នុងសន្ដាន មានភាពជាអ្នកដឹងហេតុជាដើម ហៅថា សប្បុរសៗនោះឯង តែងនិយាយដឹកនាំពួកជនឲ្យជឿកម្មនិងផលរបស់កម្ម, ឲ្យជឿហេតុដែលគួរជឿ ឲ្យខ្លាចបាបឲ្យខ្ពើមអំពើទុច្ចរិត, ឲ្យតក់ស្លុតខ្លាចបាប រកាចិត្តចំពោះអំពើទុច្ចរិត, ឲ្យខំឧស្សាហ៍រៀន, ឲ្យមានសេចក្ដីព្យាយាមក្នុងកុសលធម៌ ឲ្យមានស្មារតីសេចក្ដីរឭកត្រូវ, ឲ្យមានបញ្ញាការដឹងសព្វទាំងផ្លូវលោកផ្លូវធម៌គ្មានចន្លោះ មួយទៀត លោកតែងនិយាយពាក្យដែលនាំឲ្យមានប្រាថ្នាតិច, នាំឲ្យមានសន្ដោសដោយបច្ច័យតាមមានតាមបាន, នាំឲ្យស្ងាត់កាយស្ងាត់ចិត្ត នាំមិនឲ្យច្រឡូកច្រឡំដោយបក្សពួក នាំឲ្យមានព្យាយាមមាំមួន នាំឲ្យតាំងនៅក្នុងសីល នាំឲ្យមានសមាធិចិត្ត នាំឲ្យកើតប្រាជ្ញាស្គាល់ការណ៍

ដ៏ជ្រាលជ្រៅ នាំឲ្យធ្វើចិត្តផុតចាកកិលេស នាំឲ្យកើតការដឹងឃើញក្នុងវិមុត្តិ ពាក្យយ៉ាងនេះជាដើម ហៅថា សទ្ធម្មស្សវនា ។

មិច្ឆាទិដ្ឋិបុគ្គល កាលបើបានចូលទៅគប់រកទីពឹងសប្បុរសនោះ ហើយបានតាំងចិត្តប្រុងស្តាប់ធម៌លោកដោយគោរព រមែងធ្វើទិដ្ឋិឲ្យត្រង់ទៅរកផ្លូវពិត ដែលហៅថា សម្មាទិដ្ឋិ អធិប្បាយមកនេះ ត្រូវគ្នានឹងអានិសង្សស្តាប់ធម៌ទី៤ថា ទិដ្ឋឹ ឧជុំ ករោតិ "អ្នកស្តាប់ធម៌រមែងធ្វើទិដ្ឋិឲ្យត្រង់" សេចក្តីនេះបង្ហាញឲ្យឃើញថា មិច្ឆាទិដ្ឋិនឹងប្រែក្លាយទៅជាសម្មាទិដ្ឋិបានដោយវិធីស្តាប់ធម៌របស់សប្បុរស ដែលហៅថា សទ្ធម្ម-ស្សវនា ដូចមិគារសេដ្ឋី កាលស្តាប់ធម៌ព្រះទសពលក៏បានសម្រេចសោតា-បត្តិផលដល់នូវភាពជាអរិយបុគ្គលក្នុងពុទ្ធសាសនា រឿងនេះមានសំដែងរួចមកហើយ ឬក៏ដូច

## រឿងភារទ្វាជព្រាហ្មណ៍ [១]

សេចក្តីថា នាងធនញ្ជានីព្រាហ្មណី ជាប្រពន្ធរបស់ព្រាហ្មណ៍មិច្ឆាទិដ្ឋិឈ្មោះភារទ្វាជៈ ជាស្រីបានសម្រេចដល់ថ្នាក់សោតាបត្តិផល ។ នាងកណ្តាសក្តី ក្អកក្តី ភ្លាត់មាត់ក្តី តែងបន្លឺវាចាថា នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។ ក្នុងថ្ងៃមួយដែលជាវេលាជួបជុំព្រាហ្មណ៍មិច្ឆាទិដ្ឋិច្រើននាក់, នាងភ្លាត់មាត់បន្លឺវាចានោះឯង ។

---

១ មានក្នុងគម្ពីរធម្មបទដ្ឋកថា ភាគ ៨ ត្រង់ព្រាហ្មណវគ្គ ។

ភារទ្វាជព្រាហ្មណ៍ក៏ខឹង ហើយស្ដីបន្ទោសថា "មេចោរព្រៃនេះ សរសើរស្រមណ៍កំណាច ក្នុងទីមិនគួរសរសើរយ៉ាងនេះ, ហេងឯងចាំមើល អញនឹងទៅដេញដោលសួរគ្រូហេងឯង ក្នុងកាលឥឡូវនេះ" ថាហើយក៏ដើរចេញទៅកាន់សំណាក់ព្រះសាស្ដា តែមិនថ្វាយបង្គំទេ ឈរក្នុងទីគួរមួយ ទូលសួរជូរចេះថា:

កឹសុ ឃត្វា សុខំ សេតិ កឹសុ ឃត្វា ន សោចតិ
កិស្សស្សុ ឯកធម្មស្ស វធំ រោចេសិ គោតម

គេសម្លាប់អ្វីដេកជាសុខ សម្លាប់អ្វីមិនសោកស្ដាយ បពិត្រព្រះគោតម! ព្រះអង្គទ្រង់ពេញព្រះរាជហឫទ័យចំពោះការសម្លាប់ធម៌ណាជាធម៌ឯក ។

ព្រះសាស្ដាទ្រង់ត្រាស់ដោះប្រស្នានេះ ដោយព្រះគាថាយ៉ាងនេះថា

កោធំ ឃត្វា សុខំ សេតិ កោធំ ឃត្វា ន សោចតិ
កោធស្ស វិសមូលស្ស មធុរគ្គស្ស ព្រាហ្មណ
វធំ អរិយា បសំសន្តិ តញ្ហិ ឃត្វា ន សោចតិ

គេសម្លាប់សេចក្ដីក្រោធដេកជាសុខ សម្លាប់សេចក្ដីក្រោធមិនសោកស្ដាយ ម្នាលព្រាហ្មណ៍ ពួកអរិយៈតែងសរសើរចំពោះការសម្លាប់សេចក្ដីក្រោធថាជាធម៌ឯក ដែលមានគល់លាយដោយពិស មានចុងឆ្ងាញ់ក្រៃពេក បើជនសម្លាប់សេចក្ដីក្រោធនោះបាន រមែងមិនទុកស្ដាយឡើយ ។

(មានត)

# ព្រះគ្រូមហាបទុម អាយ–ស៊ុន ក្រុមជំនុំព្រះត្រៃបិដក

រៀបរៀង (តមក)

មាតាបិតាមានឧបការគុណដល់បុត្តធីតាយ៉ាងធំទូលាយ យ៉ាងនេះ ទើបមានពាក្យពោលជានេមិត្តនាមទុកមកដោយពុទ្ធភាសិតថា

ព្រហ្មាតិ មាតាបិតរោ បុព្វាចរិយាតិ វុច្ចរេ
អាហុនេយ្យា ច បុត្តានំ បជាយ អនុកម្បកា

សេចក្តីថា មាតាបិតាទុកជាព្រហ្មផង ជាបុព្វាចារ្យផង ជាអាហុនេយ្យបុគ្គលផង របស់បុត្តធីតា គឺជាអ្នកអនុគ្រោះចំពោះបុត្តធីតា ។ មាតាបិតាធ្វើកិច្ចចំទុកបំរុងបុត្តធីតា ដោយសេចក្តីនឿយលំបាកយ៉ាងនេះ ទើបឈ្មោះថាជាអ្នកទ្រង់គុណដ៏ធំ បុត្តធីតាត្រូវតែធ្វើបដិការតបគុណលោកទាំងនោះកុំបីអាក់ខាន បើបុត្តធីតាប្រព្រឹត្តខុសក្នុងមាតាបិតាហើយរមែងទទួលទោសដ៏ធ្ងន់ សមដូចភាសិតថា

យំ កិញ្ចាកតោ ចោរោ មាតុអបរាធកោ
មាតរិ មិច្ឆា ចរិត្វាន និរយំ សោ ឧបបជ្ជតិ
យំ កិញ្ចាកតោ ចោរោ បិតុអបរាធកោ
បិតរិ មិច្ឆា ចរិត្វាន និរយំ សោ ឧបបជ្ជតិ

សេចក្ដីថា កូនប្រុសស្រីឯណាដែលមាតាបិតាបានចិញ្ចឹមមកហើយដោយសេចក្ដីលំបាក ហើយត្រឡប់ជាមិនទំនុកបំរុងចិញ្ចឹមមាតាបិតាវិញ កូនប្រុសស្រីនោះលុះស្លាប់ទៅរមែងទៅកើតក្នុងនរក ព្រោះប្រព្រឹត្តខុសចំពោះមាតាបិតា ។ ហេតុនោះបុត្តធីតាត្រូវតែគោរពប្រតិបត្តិមាតាបិតារបស់ខ្លួន ដើម្បីលើកខ្លួនឲ្យផុតចាកអបាយមាននរកជាដើម ។ កិច្ចការទំនុកបំរុងមាតាបិតានោះ ពោលដោយប្រភេទមាន ៥ ប្រការ គឺ ១- ភតោ នេ ភរិស្សាមិ កូនត្រូវតាំងចិត្តថា លោកបានចិញ្ចឹមអាត្មាអញហើយអាត្មាអញត្រូវចិញ្ចឹមលោកវិញ; ២- កិច្ចំ នេសំ ករិស្សាមិ ត្រូវធ្វើកិច្ចការរបស់លោក, ៣- កុលវំសំ ឋបេស្សាមិ ត្រូវថែទាំតម្កល់វង្សត្រកូលឲ្យតាំងនៅឋិតថេរចិរកាល ៤- ទាយជ្ជំ បដិបជ្ជាមិ ត្រូវប្រតិបត្តិខ្លួនឲ្យសមគួរនឹងទទួលកេរ្តិ៍មតក, ៥- ទក្ខិណំ អនុប្បទស្សាមិ កាលលោកលាចាកខ្លួនទៅកាន់បរលោកហើយ ត្រូវធ្វើទក្ខិណានុប្បទានឧទ្ទិសផលជូនទៅតាមកាលគួរ ។

ខទី ១ បានដល់ការចិញ្ចឹមលោកដោយអាហារគ្រឿងបរិភោគ និងគ្រឿងឧបភោគមានសម្លៀកបំពាក់ទីដេកលំនៅជាដើម, ការបម្រើទាំងអម្បាលនេះ ជាកិច្ចដែលបុត្តធីតាត្រូវធ្វើចំពោះមាតាបិតាតាមឋានៈរបស់ខ្លួន ។ ខទី ២ កិច្ចការងាររបស់មាតាបិតា កូនប្រុសស្រីគប្បីធ្វើដោយខ្លួនឯង កុំឲ្យលោកមានចិត្តធុញលំបាកនឹងកិច្ចនោះៗ ។ ខទី ៣ ថែទាំ

ដម្រង់វង្សត្រកូលឲ្យគង់ស្ថិតស្ថេរ គឺជួយការពារកេរ្តិ៍តករបស់លោកកុំឲ្យវិនាស ឬក៏នោះសោត ការបុណ្យកុសលឯណាមួយដែលជាកិច្ចធ្លាប់មានមកក៏ត្រូវគោរពទុកកុំឲ្យសាបសូន្យ ។ ទី៤ ប្រព្រឹត្តខ្លួនឲ្យជាអ្នកសមគួរនឹងទទួលទ្រព្យមត៌ក គឺគោរពប្រតិបត្តិឲ្យលោកពេញចិត្តក្នុងសេចក្តីប្រព្រឹត្តិរបស់ខ្លួនដែលជាអ្នកសាបរក្សាទ្រព្យមត៌កផង ។ ទី១ ២-៣-៤ ជានាទីរបស់បុត្រធីតា ត្រូវធ្វើចំពោះមាតាបិតា ក្នុងពេលដែលលោកនៅមានជីវិត ។ ឯទី៥ ត្រូវធ្វើក្នុងពេលដែលលោកអស់ជីវិតទៅ ដោយការធ្វើកាយវាចាចិត្តរបស់ខ្លួនឲ្យជាកុសលហើយធ្វើទក្ខិណាទានឧទ្ទិសផលជូនទៅ ។ បុគ្គលអ្នកប្រកបការបម្រើមាតាបិតាដូចបានពោលមកនេះ ឈ្មោះថាជាអ្នកធ្វើខ្លួនមិនឲ្យមានសេចក្តីក្តៅក្រោយ ហើយបណ្ឌិតតែងសរសើរថាជាអ្នកមានកតញ្ញូកតវេទិតាធម៌ រមែងមានបីតិប្រាមោជ្ជៈប្រព្រឹត្តទៅក្នុងចិត្ត អស់យប់នឹងថ្ងៃជានិរន្តរ៍ សូម្បីសម្តេចព្រះបរមសាស្តា ក៏ទ្រង់សរសើរទុកដោយគាថា ដែលមានមកក្នុងព្រហ្មសូត្រថា

តាយ នំ បរិចរិយាយ មាតាបិត្តុសុ បណ្ឌិតា
ឥធេវ នំ បសំសន្តិ បេច្ច សគ្គេ បមោទតិ

សេចក្តីថា បណ្ឌិតទាំងឡាយ រមែងសរសើរបុគ្គលក្នុងលោកនេះ ព្រោះការទំនុកបំរុងចិញ្ចឹមមាតាបិតា បុគ្គលនោះលុះលះ

លោកនេះទៅហើយ ក៏រមែងត្រេកអររីករាយក្នុងឋានសួគ៌ ។ ព្រោះហេតុនេះបុគ្គលគាប្បីតបស្នងដល់ឧបការគុណរបស់មាតាបិតា ដែលមានដល់ខ្លួនហើយក្នុងកាលមុន គប្បីតាំងចិត្តធ្វើបដិការតបគុណលោកដោយស្ថាន ៤ ប្រការដូចបានពោលហើយនោះឲ្យគ្រប់បរិបូណ៌, យ៉ាងនេះឯងទើបអាចញុំាងសេចក្តីសុខ - ចំរើននិងប្រយោជន៍ឲ្យសម្រេចក្នុងលោកទាំង ២ ដោយអនេកប្រការ ។

## ២– កុលេ ជេដ្ឋាបចាយនៈ

« ការប្រព្រឹត្តិបំអោនលំទោនចំពោះជេដ្ឋបុគ្គលក្នុងត្រកូល »

ជេដ្ឋបុគ្គល ឬ វុឌ្ឍបុគ្គលសំដែងដោយប្រភេទមាន ៣ យ៉ាងគឺ

១- ជាតិវុឌ្ឍ បុគ្គលចាស់ដោយជាតិបានដល់លោកអ្នកខ្ពង់ខ្ពស់ដោយជាតិដែលពួកជនសំគាល់ថាជាធំក្នុងលោក មានព្រះមហាក្សត្រជាដើម

២- វយវុឌ្ឍ បុគ្គលចាស់ដោយវ័យ បានដល់លោកអ្នកខ្ពង់ខ្ពស់ដោយអាយុគឺជាព្រឹទ្ធាចារ្យមានអាយុច្រើន; ៣ -- គុណវុឌ្ឍ បុគ្គលចាស់ដោយគុណ បានដល់អ្នកទ្រង់គុណសម្បត្តិ គឺសេចក្តីល្អក្នុងសន្តានមានសីលគុណជាដើម ។ វុឌ្ឍបុគ្គលទាំង ៣ ប្រភេទនេះ ជាអ្នកសមគួរដល់ជនអ្នកចាប់កំណើតដោយជាតិ វ័យអាយុនិងគុណសម្បត្តិគប្បីគោរពរាប់អាន ដោយអាការត្រឹមតែសាមីចិកម្ម គឺសេចក្តីកោតក្រែងប៉ុណ្ណោះ ក៏អាចខំនឹងបន្ទោបង់នូវមានះទិដ្ឋិនិងមាយា (មានត)